# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
និង
របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ
សម្រាប់ សហគ្រាសធុនតូច និង មធ្យម

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និង សម្រាប់ការិយបរិច្ឆេទបញ្ចប់

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## មាតិកា

*ទំព័រ*


របាយការណ៍របស់ក្រុមប្រឹក្សាភិបាល........................................1 - 5

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

របាយការណ៍របស់សវនករឯករាជ្យ ........................................6 - 9

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........................................10

របាយការណ៍លទ្ធផលពេញលេញ........................................11

របាយការណ៍បម្រែបម្រួលមូលធន........................................12 - 13

របាយការណ៍លំហូរសាច់ប្រាក់ ........................................14

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ........................................15 - 51

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ("ក្រុមហ៊ុន") បង្ហាញរបាយការណ៍របស់ខ្លួនរួមជាមួយ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណ និងបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត តាមបញ្ជីការលេខ Co. 0700 KH/2010 ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2010។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអាជីវកម្មជាអចិន្ត្រៃយ៍ពីធនាគារជាតិ នៃ កម្ពុជា ក្នុងការធ្វើប្រតិបត្តិការសេវាកម្មមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី29 ខែកក្កដា ឆ្នាំ2010។

ទស្សនៈវិស័យរបស់ក្រុមហ៊ុនគឺក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានទំនុកចិត្ត ហើយផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខ ដល់ប្រជាជនកម្ពុជា និងធានាអោយបាននូវអត្ថប្រយោជន៍របស់អតិថិជន និយោជិក ភាគទុនិក និងសហគមន៍ទាំងមូល។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខ និងផ្តល់ផលវិជ្ជមានជានិរន្តរ៍ទៅសហគមន៍ សហគ្រាសធុនតូច និងមធ្យម កសិករ ជាពិសេសស្ត្រី ដោយមានទំនួលខុសត្រូវខ្ពស់។

អាសយដ្ឋានក្រុមហ៊ុនដែលបានចុះបញ្ជី ស្ថិតនៅផ្ទះលេខ101អា ផ្លូវលេខ289 សង្កាត់បឹងកក់ទី1 ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

## ដើមទុន

ក្នុងអំឡុងការិយបរិច្ឆេទនេះ ក្រុមហ៊ុនបានបង្កើនដើមទុនចំនួន 1,490,000 ដុល្លារអាមេរិក *(កំណត់សម្គាល់លេខ 15)*។

## ភាគលាភ

ក្នុងអំឡុងការិយបរិច្ឆេទនេះមិនមានការប្រកាសភាគលាភនោះទេ។

## ទុនបម្រុង និងសំវិធានធន

មិនមានបម្រែបម្រួលជាសារវន្តលើទុនបម្រុង និង សំវិធានធនសម្រាប់ការិយបរិច្ឆេទនេះទេ លើកលែងតែបម្រែបម្រួល ដែលត្រូវបានលាតត្រដាងបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។



គ្រឹះស្ថានឯកជន
Private Company
ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS # 101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (855) 23 996 936, 023 533 9999 WEBSITE: WWW.CAMMA.COM.KH

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

### ឥណទាន និងបុរេប្រទាន អាក្រក់ និងជាប់សង្ស័យទៅអតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និង ការធ្វើសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថា រាល់ឥណទានអាក្រក់ដែលបានដឹង ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានប៉ាន់ស្មានគ្រប់គ្រាន់សម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើបំណុលអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្ត នោះទេ។

### ទ្រព្យសកម្មចរន្ត

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយទ្រព្យសកម្មចរន្ត (លើកលែងតែពាក់ព័ន្ធជាមួយឥណទាន) ដែលទំនងជាមិនអាចទទួលស្គាល់ក្នុងតំលៃដើម ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុននោះ ត្រូវបានកាត់បន្ថយតម្លៃយកស្មើនឹងតម្លៃដែលគេរំពឹងទុកថាអាចទទួលយកបាន។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលអាចបណ្តាលអោយការកំណត់តម្លៃនៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានការយល់ច្រឡំ និងមានភាពមិនសមស្របជាសារវន្តនោះទេ។

### វិធីសាស្ត្រកំណត់តម្លៃ

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និង ធ្វើអោយប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនាំអោយមានការយល់ច្រឡំ និងមានភាពមិនសមស្របជាសារវន្តនោះទេ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- គ្មានការដាក់បន្ទុកណាមួយដែលកើតចេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន ក្នុងការធានាបំណុលរបស់បុគ្គលដទៃចាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះទេ។
- គ្មានបំណុល យថាហេតុទាក់ទងដល់ក្រុមហ៊ុន ដែលបានកើតឡើងចាប់ពីចុងនៃការិយបរិច្ឆេទ នៃរបាយការណ៍នេះ ក្រៅពីបំណុលដែលមានទំនាក់ទំនងជាមួយសកម្មភាពអាជីវកម្មធម្មតារបស់ក្រុមហ៊ុននោះទេ។

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

### បំណុលយថាហេតុ និងបំណុលផ្សេងៗ (តពីទំព័រមុន)

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល គ្មានបំណុលយថាហេតុ ឬ បំណុលផ្សេងៗ របស់ក្រុមហ៊ុនដែលអាច ឬ ទំនងក្លាយជាកាតព្វកិច្ចក្នុងអំឡុងពេល 12 ខែ បន្ទាប់ពីចុងនៃការិយបរិច្ឆេទនៃរបាយការណ៍នេះ នឹងមាន ឬអាចមានផលប៉ះពាល់ជាសារវន្តលើសមត្ថភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលទាំងនោះដល់ពេលទូទាត់។

### ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃការរាយការណ៍

មិនមានព្រឹត្តិការណ៍សំខាន់ណាមួយ បានកើតឡើងក្រោយកាលបរិច្ឆេទនៃការរាយការណ៍ដែលតម្រូវអោយមានការលាតត្រដាងព័ត៌មាន ឬ ធ្វើនិយ័តភាព លើកលែងតែព្រឹត្តិការណ៍ដូចដែលបានលាតត្រដាងបង្ហាញនៅក្នុងកំណត់សម្គាល់ ដែលមានភ្ជាប់ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

### ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុងការិយបរិច្ឆេទ និង នៅកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោក ធន់ វឌ្ឍនា | ប្រធានក្រុមប្រឹក្សាភិបាល |
| លោកស្រី ខាត់ សុខគាន | អនុប្រធានក្រុមប្រឹក្សាភិបាល |
| លោក ខូវ សូវៀត | សមាជិកក្រុមប្រឹក្សាភិបាល |

### សវនករ

ក្រុមហ៊ុនសវនកររងករាជ្យ Ernst & Young (Cambodia) Ltd គឺជាសវនកររបស់ក្រុមហ៊ុន។

### ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាសភាពនៃក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនទេ។

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនៅចុងការិយបរិច្ឆេទនេះ មិនមានកិច្ចព្រមព្រៀងណាមួយ (ក្នុងនោះក្រុមហ៊ុនជាភាគីម្ខាង) ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចបង្កលទ្ធភាពដល់សមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍ តាមមធ្យោបាយផ្សេងៗ ដូចជា ការទិញភាគហ៊ុន ឬ ប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬ របស់សាជីវកម្មដទៃ។

ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈហេតុផលនៃកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬ ជាមួយនឹងក្រុមហ៊ុនដែលអភិបាលនោះ ជាសមាជិកក្រុមប្រឹក្សាភិបាល ឬ ក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានផលប្រយោជន៍ហិរញ្ញវត្ថុជាសារវន្ត លើកលែងតែអត្ថប្រយោជន៍ទាំងឡាយណាដែលត្រូវបានលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

## របាយការណ៍ស្តីពី ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និងលទ្ធផលនៃប្រតិបត្តិការ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់។ ក្រុមប្រឹក្សាភិបាល ត្រូវពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលធ្វើឡើងដោយគណៈគ្រប់គ្រងដែលត្រូវបានតំរូវអោយៈ

- អនុម័តគោលនយោបាយគណនេយ្យសមស្របដោយមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល និងប្រុងប្រយ័ត្នហើយត្រូវអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍។
- អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs") ប្រសិនបើមានគំលាតនៃការអនុវត្ត ដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិតនិងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គំលាតទាំងនោះគួរតែត្រូវបានលាតត្រដាងព័ត៌មានពន្យល់ និងកំណត់ចំនួនទឹកប្រាក់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុអោយបានសមរម្យ។
- រក្សាទុកបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និងធានាថាប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាព លើកលែងតែក្នុងករណីដែលក្រុមហ៊ុនមិនអាចបន្តសកម្មភាពអាជីវកម្មនាពេលអនាគត និង
- បង្កើតគោលនយោបាយទូទៅសម្រាប់ក្រុមហ៊ុនអនុម័តរាល់ការសំរេចចិត្ត និងសកម្មភាពទាំងឡាយរបស់ ក្រុមប្រឹក្សាភិបាលដែលមានឥទ្ធិពលលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយនិងធានាថាគោលនយោបាយ និងការសំរេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របក្នុង របាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យដែលត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអោយបានត្រឹមត្រូវ សមហេតុផលគ្រប់ពេល ហើយនិង ធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានអនុវត្ត។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន ហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ និង ស្វែងរកកំហុសចេតនា និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ ជាក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដូចដែលមានភ្ជាប់ជាមួយនេះដែលបាន ផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាកាលបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាម CIFRS for SMEs។

តំណាងក្រុមប្រឹក្សាភិបាល

ធន់ ឡៀនា
ប្រធានក្រុមប្រឹក្សាភិបាល

ឌិត នីតា
ប្រធាននាយកប្រតិបត្តិ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី8 ខែ ឧសភា ឆ្នាំ2020

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
#64 Norodom Boulevard corner Street 178
Sangkat Chey Chumneah, Khan Daun Penh
12206 Phnom Penh, Kingdom of Cambodia

Tel: +855 23 860 450/451
Fax: +855 23 217 805
ey.com

លេខយោង៖ 61522920-21298813

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ ភាគទុនិកនៃ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### *មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ("ក្រុមហ៊ុន") ដែលមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និង របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះ បង្ហាញនូវទិដ្ឋភាពពិតប្រាកដ និង ត្រឹមត្រូវ លើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិង លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និង មធ្យម ("CIFRS for SMEs")។

### *មូលដ្ឋាននៃមតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ត្រូវបានបរិយាយបន្ថែម នៅក្នុងផ្នែកនៃ *"ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ"* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងតាមអនុក្រឹត្យស្តីពីក្រមសីលធម៌និងវិជ្ជាជីវៈរបស់គណនេយ្យករ និងសវនករជំនាញ ដែលចេញដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំ ក៏បានបំពេញនូវទំនួលខុសត្រូវវិជ្ជាជីវៈដទៃទៀតយោងតាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំ ជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំ ទទួលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យផ្សេងទៀត ដែលបានបញ្ចេញមតិយោបល់ត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ នាថ្ងៃទី30 ខែមេសា ឆ្នាំ2019។

## *ព័ត៌មានផ្សេងៗ*

ព័ត៌មានផ្សេងៗ ដែលបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដូចដែលបានបង្ហាញក្នុងទំព័រទី1 ដល់ទី5។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗ នេះដែរ។

ទាក់ទងនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណា ថាតើព័ត៌មានផ្សេងៗនេះ មានភាពខុសគ្នាជាសារវន្តឬទេ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការងារសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះមានកំហុសឆ្គងជាសារវន្តឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

## *ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ*

គណៈគ្រប់គ្រងក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាម CIFRS for SMEs ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬបញ្ឈប់ប្រតិបត្តិការណ៍ក្រុមហ៊ុន ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការនៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលមាននោះទេ ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

Building a better
working world

***ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង កំហុសឆ្គងដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងនៅក្នុងប្រព័ន្ធគណនេយ្យ និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានលើវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ កាលៈទេសៈទាំងឡាយណា ដែលនាំឲ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។
- វាយតម្លៃការដាក់បង្ហាញ ទម្រង់ និងមាតិកាទាំងស្រុងនៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការណ៍ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

Building a better
working world

***ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាពដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ឡូន ស៊ុនរតនា
Partner

Ernst & Young (Cambodia) Ltd.
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី8 ខែឧសភា ឆ្នាំ2020

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| | *កំណត់សម្គាល់* | *2019* | | *2018* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2) (ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 224,616 | 915,310 | 186,706 | 750,185 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 6 | 181,889 | 741,198 | 106,593 | 428,291 |
| សមតុល្យនៅធនាគារផ្សេងៗ | 7 | 11,429 | 46,573 | 669,259 | 2,689,083 |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 8 | 12,840,197 | 52,323,803 | 10,119,305 | 40,659,367 |
| ទ្រព្យសកម្មផ្សេងៗ | 9 | 75,367 | 307,121 | 69,676 | 279,958 |
| អចលនទ្រព្យ និងបរិក្ខារ | 10 | 27,085 | 110,371 | 30,205 | 121,364 |
| កម្មវិធីកុំព្យូទ័រ | 11 | 18,727 | 76,313 | 31,085 | 124,900 |
| ពន្ធពន្យាជាទ្រព្យសកម្ម | 12 | 71,624 | 291,868 | 63,103 | 253,548 |
| **ទ្រព្យសកម្មសរុប** | | **13,450,934** | **54,812,557** | **11,275,932** | **45,306,696** |
| **ទ្រព្យអកម្ម និងមូលនិធិម្ចាស់ភាគហ៊ុន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| បំណុលពន្ធលើប្រាក់ចំណេញ | 12.2 | 92,621 | 377,432 | 55,366 | 222,461 |
| ប្រាក់កម្ចី | 13 | 8,955,329 | 36,492,966 | 8,190,698 | 32,910,225 |
| បំណុលផ្សេងៗ | 14 | 164,618 | 670,818 | 94,355 | 379,119 |
| **ទ្រព្យអកម្មសរុប** | | **9,212,568** | **37,541,216** | **8,340,419** | **33,511,805** |
| **មូលនិធិម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 15 | 3,593,000 | 14,372,000 | 2,103,000 | 8,412,000 |
| ប្រាក់ចំណេញរក្សាទុក | | 575,726 | 2,352,112 | 741,526 | 2,997,963 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 16 | 69,640 | 278,597 | 90,987 | 365,586 |
| លម្អៀងបង្គរពីការប្រែសម្រួលរូបិយប័ណ្ណ | | - | 268,632 | - | 19,342 |
| **មូលនិធិម្ចាស់ភាគហ៊ុនសរុប** | | **4,238,366** | **17,271,341** | **2,935,513** | **11,794,891** |
| **ទ្រព្យអកម្ម និង មូលនិធិម្ចាស់ភាគហ៊ុនសរុប** | | **13,450,934** | **54,812,557** | **11,275,932** | **45,306,696** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 25 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ*

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| | *កំណត់សម្គាល់* | *2019* | | *2018* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| **ចំណូលប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | 17 | 2,034,345 | 8,243,166 | 1,643,920 | 6,649,656 |
| ចំណាយការប្រាក់ | 18 | (573,401) | (2,323,421) | (482,965) | (1,953,593) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **1,460,944** | **5,919,745** | **1,160,955** | **4,696,063** |
| ចំណូលប្រតិបត្តិការផ្សេងៗ | 19 | 95,928 | 388,700 | 73,915 | 298,986 |
| **ចំណូលប្រតិបត្តិការសរុប** | | **1,556,872** | **6,308,445** | **1,234,870** | **4,995,049** |
| ចំណាយបុគ្គលិក | 20 | (652,387) | (2,643,472) | (601,082) | (2,431,377) |
| រំលស់ | 10,11 | (33,496) | (135,726) | (47,649) | (192,740) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 21 | (408,112) | (1,653,670) | (260,668) | (1,054,402) |
| (សំវិធានធន) ការកត់ត្រាបញ្ច្រាស់នៃសំវិធានធន លើការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន | 8 | (66,311) | (268,692) | 32,385 | 130,997 |
| **ចំណេញមុនពេលបង់ពន្ធ** | | **396,566** | **1,606,885** | **357,856** | **1,447,527** |
| ពន្ធលើប្រាក់ចំណេញ | 12 | (93,713) | (379,725) | (21,048) | (85,139) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **302,853** | **1,227,160** | **336,808** | **1,362,388** |
| *ធាតុចំណេញពេញលេញផ្សេងៗ* | | | | | |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | | - | 249,290 | - | (58,469) |
| **ចំណេញពេញលេញសរុប** | | **302,853** | **1,476,450** | **336,808** | **1,303,919** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 25 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ*

# ខេមរា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| | *ដើមទុន* | | *ប្រាក់ចំណេញរក្សាទុក* | | *ទុនបម្រុងបទប្បញ្ញត្តិ* | | *លម្អៀងបង្គរពីការប្រែសម្រួលរូបិយប័ណ្ណ* | *សរុប* | |
|---|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* |
| **ថ្ងៃទី1 ខែមករា ឆ្នាំ2019** | 2,103,000 | 8,412,000 | 741,526 | 2,997,963 | 90,987 | 365,586 | 19,342 | 2,935,513 | 11,794,891 |
| ការបន្ថែមដើមទុន | | | | | | | | | |
| សាច់ប្រាក់ | 1,000,000 | 4,000,000 | - | - | - | - | - | 1,000,000 | 4,000,000 |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុក | 490,000 | 1,960,000 | (490,000) | (1,960,000) | - | - | - | - | - |
| ប្រាក់ចំណេញសុទ្ធ | - | | 302,853 | 1,227,160 | - | - | - | 302,853 | 1,227,160 |
| ផ្ទេរពីទុនបម្រុងបទប្បញ្ញត្តិ | - | | 21,347 | 86,989 | (21,347) | (86,989) | - | - | - |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | - | | - | - | - | - | 249,290 | - | 249,290 |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **3,593,000** | **14,372,000** | **575,726** | **2,352,112** | **69,640** | **278,597** | **268,632** | **4,238,366** | **17,271,341** |

# ខេមរា មីក្រូហិរញ្ញវត្ថុ លីមីតធីត

**របាយការណ៍បម្រែបម្រួលមូលធន** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| | *ដើមទុន* | | *ប្រាក់ចំណេញរក្សាទុក* | | *ទុនបម្រុងបទប្បញ្ញត្តិ* | | *លម្អៀងបង្កពីការប្រែសម្រួលរូបិយប័ណ្ណ* | *សរុប* | |
|---|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* |
| **ថ្ងៃទី1 ខែមករា ឆ្នាំ2018** *(ការរាយការណ៍ពីមុន)* | 2,103,000 | 8,412,000 | 498,470 | 2,012,323 | - | - | 77,811 | 2,601,470 | 10,502,134 |
| *ផលនៃការធ្វើនិយ័តកម្មអន្តរកាល (កំណត់សម្គាល់លេខ 3)* | - | - | (2,765) | (11,162) | | | - | (2,765) | (11,162) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** *(ការរាយការណ៍ឡើងវិញ- កំណត់សម្គាល់លេខ 3)* | **2,103,000** | **8,412,000** | **495,705** | **2,001,161** | - | | **77,811** | **2,598,705** | **10,490,972** |
| ប្រាក់ចំណេញសុទ្ធ *(ការរាយការណ៍ឡើងវិញ- កំណត់សម្គាល់លេខ 3)* | - | - | 336,808 | 1,362,388 | - | | - | 336,808 | 1,362,388 |
| ផ្ទេរទៅទុនបម្រុងបទប្បញ្ញត្តិ | - | - | (90,987) | (365,586) | 90,987 | 365,58 | - | - | - |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | - | - | - | - | - | | (58,469) | - | (58,469) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** *(ការរាយការណ៍ឡើងវិញ- កំណត់សម្គាល់លេខ 3)* | **2,103,000** | **8,412,000** | **741,526** | **2,997,963** | **90,987** | **365,586** | **19,342** | **2,935,513** | **11,794,891** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 25 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ*

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| | *កំណត់សម្គាល់* | *2019* | | *2018* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនគិតពន្ធ | | 396,566 | 1,606,885 | 357,856 | 1,447,527 |
| *ការធ្វើនិយ័តកម្មទៅលើ:* | | | | | |
| រំលស់អចលនទ្រព្យ និងបរិក្ខារ | 10 | 21,139 | 85,655 | 35,292 | 142,756 |
| រំលស់កម្មវិធីកុំព្យូទ័រ | 11 | 12,358 | 50,075 | 12,357 | 49,984 |
| វិសំធានធនលើការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន | | 66,200 | 268,242 | 118,631 | 479,862 |
| *បម្រែបម្រួលទ្រព្យសកម្ម និងទ្រព្យអកម្ម:* | | | | | |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 8 | (2,787,092) | (11,293,297) | (2,677,526) | (10,830,593) |
| ទ្រព្យសកម្មផ្សេងៗ | 9 | (5,693) | (23,068) | (15,971) | (64,603) |
| ប្រាក់បញ្ញើតាមតម្រូវការ | 7 | (74,500) | (301,874) | - | - |
| ទ្រព្យអកម្មផ្សេងៗ | 14 | 70,265 | 284,714 | 136,992 | 554,133 |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តការ** | | **(2,300,757)** | **(9,322,668)** | **(2,032,369)** | **(8,220,934)** |
| ពន្ធលើប្រាក់ចំណេញ | 12 | (64,979) | (263,295) | (51,210) | (207,144) |
| **លំហូរសាច់ប្រាក់សុទ្ធ ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | | **(2,365,736)** | **(9,585,963)** | **(2,083,579)** | **(8,428,078)** |
| **សកម្មភាពវិនិយោគ** | | | | | |
| *ការទិញនូវ:* | | | | | |
| អចលនទ្រព្យ និងបរិក្ខារ | 10 | **(18,019)** | **(73,013)** | **(5,559)** | **(22,486)** |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 13 | 6,625,042 | 26,844,670 | 10,771,052 | 43,568,905 |
| ការទូទាត់សងប្រាក់កម្ចី | 13 | (5,860,411) | (23,746,385) | (8,000,634) | (32,362,565) |
| សាច់ប្រាក់ទទួលបានពីការបន្ថែមដើមទុន | | 1,000,000 | 4,052,000 | - | - |
| **សាច់ប្រាក់ទទួលបានពីសកម្មភាពហិរញ្ញវត្ថុ** | | **1,764,631** | **7,150,285** | **2,770,418** | **11,206,340** |
| **ការ(ថយចុះ) កើនឡើង នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **(619,124)** | **(2,508,691)** | **681,280** | **2,755,776** |
| សាច់ប្រាក់និង សាច់ប្រាក់សមមូលដើមគ្រា | | 857,408 | 3,445,066 | 176,128 | 711,029 |
| ភាពខុសគ្នានៃការប្រែសម្រួលអត្រាប្តូររូបិយប័ណ្ណ | | - | 34,632 | - | (21,739) |
| **សាច់ប្រាក់និង សាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 5 | **238,284** | **971,007** | **857,408** | **3,445,066** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 25 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ*

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 1. ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណ និងបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត តាមបញ្ជីការលេខ Co. 0700 KH/2010 ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2010។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអាជីវកម្មជាអចិន្ត្រៃយ៍ពីធនាគារជាតិ នៃ កម្ពុជា ក្នុងការធ្វើប្រតិបត្តិការសេវាកម្មមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី29 ខែកក្កដា ឆ្នាំ2010។

ទស្សនៈវិស័យរបស់ក្រុមហ៊ុន គឺក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានទំនុកចិត្ត ហើយផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខ ដល់ប្រជាជនកម្ពុជា និងធានាអោយបាននូវអត្ថប្រយោជន៍របស់អតិថិជន និយោជិក ភាគទុនិក និងសហគមន៍ទាំងមូល។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខ និងផ្តល់ផលវិជ្ជមានជានិរន្តរ៍ទៅសហគមន៍ សហគ្រាសធុនតូច និងមធ្យម កសិករ ជាពិសេសស្ត្រី ដោយមានទំនួលខុសត្រូវខ្ពស់។

អាសយដ្ឋានក្រុមហ៊ុនដែលបានចុះបញ្ជី ស្ថិតនៅផ្ទះលេខ101អា ផ្លូវ289 សង្កាត់បឹងកក់ទី1 ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

*និយោជិត*

និយោជិតទាំងអស់របស់ក្រុមហ៊ុននាកាលបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 មានចំនួន 103នាក់ (2018៖ 94 នាក់)។

*សេចក្តីអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ*

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តអោយចេញផ្សាយ ដោយក្រុមប្រឹក្សាភិបាលនៅ ថ្ងៃទី8 ខែឧសភា ឆ្នាំ2020។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ

*មូលដ្ឋាននៃបទបង្ហាញ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក និងរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។ ក្រុមហ៊ុនរក្សាកំណត់ត្រាគណនេយ្យជាប្រាក់ដុល្លារអាមេរិក ។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 គឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុនដែលធ្វើឡើងដោយអនុលោមតាម CIFRS for SMEs ។ ថ្ងៃអន្តរកាលដែលក្រុមហ៊ុនធ្វើការផ្លាស់ប្តូរការរៀបរៀងរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRS for SMEs គឺនៅថ្ងៃទី1 ខែមករា ឆ្នាំ2018។ របាយការណ៍ហិរញ្ញវត្ថុរបស់ការិយបរិច្ឆេទមុនៗ និងរហូតដល់ការិយបរិច្ឆេទ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និង បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា (ជារួមហៅកាត់ថា គោលការណ៍គណនេយ្យពីមុន ឬ GAAP)។

## 2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*មូលដ្ឋាននៃបទបង្ហាញ* (តពីទំព័រមុន)

អាស្រ័យដូចនេះ ក្រុមហ៊ុនបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាម CIFRS for SMEs អនុវត្តនៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 រួមជាមួយទិន្នន័យប្រៀបធៀបនិងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅថ្ងៃអន្តរកាលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ នៅថ្ងៃទី1 ខែមករា ឆ្នាំ2018 ដែលជាកាលបរិច្ឆេទនៃការផ្លាស់ប្តូរការរៀបរៀងរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRS for SMEs។

ការធ្វើការផ្លាស់ប្តូរទៅ CIFRS for SMEs បានបណ្តាលឱ្យមានការផ្លាស់ប្តូរមួយចំនួននៅក្នុងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន បើប្រៀបធៀបទៅនឹងគោលការណ៍ដែលបានប្រើតាមGAAP។ កំណត់សំគាល់លេខ3 របស់របាយការណ៍ហិរញ្ញវត្ថុបានពិពណ៌នាអំពីភាពខុសគ្នារវាងមូលធន និងប្រាក់ចំណេញ ឬការខាតបង់ដែលបានបង្ហាញក្រោម GAAP និងចំនួនទឹកប្រាក់ដែលត្រូវបានបង្ហាញថ្មីក្រោម CIFRS for SMEs នាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ក៏ដូចជាមូលធនដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដំបូងនៅថ្ងៃទី1 ខែមករា ឆ្នាំ2018។

ការកែសម្រួលពីទឹកប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុវត្តតាមច្បាប់គណនេយ្យនិងសវនកម្មរួមទាំង ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យមនៃកម្ពុជា ដែលពាក់ព័ន្ធ ដោយប្រើអត្រាមធ្យមនិងអត្រាចុងគ្រា ដូចដែលបានប្រកាស ដោយអគ្គនាយកដ្ឋានពន្ធដារកម្ពុជា។

ទ្រព្យសកម្មនិងបំណុលត្រូវបាន ប្រែសម្រួលតាមអត្រាចុងគ្រាតាមកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ចំណែកឯចំណូលនិងចំណាយត្រូវបាន ប្រែសម្រួលតាមអត្រាជាមធ្យមភាគសម្រាប់ការិយបរិច្ឆេទបញ្ចប់។ រាល់ចំនួនទឹកប្រាក់នៃភាពខុសគ្នានៃការប្រែសម្រួលអត្រាប្តូរប្រាក់ត្រូវបានចាត់ថ្នាក់ជា ធាតុដាច់ដោយឡែកនៅក្នុងមូលធន ។ ការផ្លាស់ប្តូរបែបនេះមិនគួរត្រូវបានតំណាងជាចំនួនដុល្លារអាមេរិក ឬដែលអាចត្រូវបានប្តូរទៅជាប្រាក់រៀលក្នុងអត្រាមួយផ្សេងទេ។

តម្លៃទាំងអស់ជាដុល្លាអាមេរិក និងប្រាក់រៀលត្រូវបានបង្គត់ទៅជា ដុល្លារអាមេរិក និងខ្ទង់ពាន់រៀលនូវចំនួនមួយដែលជិតបំផុត លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀលដោយផ្អែកលើអត្រាប្តូរប្រាក់ដែលត្រូវអនុវត្តក្នុង 1 ដុល្លារអាមេរិកដូចខាងក្រោម៖

| | *2019* | *2018* |
|---|---|---|
| អត្រាចុងគ្រា | 4,075 | 4,018 |
| អត្រាជាមធ្យម | 4,052 | 4,045 |

*សារពើពន្ធ*

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនចាប់ផ្តើមនៅថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

## 2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*មុខងារនិងការបង្ហាញរូបិយប័ណ្ណ និងអត្រាប្តូររូបិយប័ណ្ណបរទេស*

រូបិយប័ណ្ណជាតិរបស់កម្ពុជាគឺប្រាក់រៀល។ ទោះយ៉ាងណានៅពេលក្រុមហ៊ុនធ្វើអាជីវកម្មនិងរក្សាកំណត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងវាស់វែងនិងធ្វើបទបង្ហាញព្រោះវាឆ្លុះបញ្ចាំង ពីខ្លឹមសារសេដ្ឋកិច្ចរាល់ព្រឹត្តិការណ៍ និងគ្រប់កាលៈទេសៈទាំងអស់របស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់ដុល្លារ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់បរទេសដែលសម្រេចនៅកាលបរិច្ឆេទប្រតិបត្តិការ។ ទ្រព្យសកម្មនិងបំណុលដែលគិតជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារដែលពុំទាន់ដោះស្រាយនៅកាលបរិច្ឆេទរបាយការណ៍ ត្រូវ បានបង្ហាញនៅក្នុងរបាយការណ៍ ដោយប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ នៅកាលបរិច្ឆេទនោះ។ ភាពខុសគ្នានៃការផ្លាស់ប្តូរដែលកើតឡើងលើការកែសម្រួលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

*ឧបករណ៍ហិរញ្ញវត្ថុ*

ក្រុមហ៊ុនជ្រើសរើសវិធានគណនេយ្យចែងក្នុង ផ្នែកទី11ស្តីពី ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន និង ផ្នែកទី 12 ស្តីពី ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុដទៃទៀតមកអនុវត្ត។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់តែនៅពេលដែលអង្គភាពក្លាយជាភាគី នៃកិច្ចសន្យាពាក់ព័ន្ធនឹងឧបករណ៍នោះ។ ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូងទៅតាមតម្លៃនាពេលប្រតិបត្តិការ លើកលែងតែកិច្ចសន្យាមានប្រតិបត្តិការហិរញ្ញប្បទាន។ ប្រតិបត្តិការហិរញ្ញប្បទាន អាចនឹងកើតឡើងប្រសិនបើការទូទាត់ត្រូវបានពន្យារពេលលើសពីរយៈពេលអាជីវកម្មធម្មតា ឬការទូទាត់ត្រូវបានផ្តល់ហិរញ្ញប្បទានតាមអត្រាការប្រាក់ដែលមិនមែនជាអត្រាទីផ្សារ។ ប្រសិនបើកិច្ចសន្យានាំឲ្យមានប្រតិបត្តិការហិរញ្ញប្បទានកើតមាន ក្រុមហ៊ុនត្រូវវាស់វែងទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ តាមតម្លៃជាក់ស្តែងនៃការទូទាត់នាពេលអនាគតបញ្ចុះមកត្រឹមអត្រាការប្រាក់លើទីផ្សារសម្រាប់ឧបករណ៍បំណុលប្រហាក់ប្រហែល។

ថ្លៃដើមបន្ទុកប្រតិបត្តិការត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងអស់លើកលែងតែ ឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃទីផ្សារតាមរយៈប្រាក់ចំណេញ ឬខាត។

បន្ទាប់ពីការទទួលស្គាល់ដំបូង មូលដ្ឋានឧបករណ៍ហិរញ្ញវត្ថុទាំងអស់នឹងត្រូវបានវាស់វែងតាមថ្លៃដើមដែលបានរំលស់ ដោយប្រើវិធីសាស្រ្តគណនាការប្រាក់ប្រកបដោយប្រសិទ្ធភាព ("EIR")។

នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ក្រុមហ៊ុនត្រូវវាយតម្លៃថាតើមានភស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃរបស់ទ្រព្យសកម្មហិរញ្ញវត្ថុណាមួយដែលត្រូវវាស់វែងដោយថ្លៃដើមឬ ថ្លៃដើមដែលបានរំលស់។ ប្រសិនបើមានភស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃ ក្រុមហ៊ុនត្រូវទទួលស្គាល់ការខាតបង់លើការថយចុះតម្លៃនៅក្នុងចំណេញឬខាតជាបន្ទាន់។

## 2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***ឧបករណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយថ្លៃដើមដែលបានរំលស់ ការខាតបង់លើការថយចុះតម្លៃគឺជាភាពខុសគ្នារវាងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម និងតម្លៃជាក់ស្តែងនៃលំហូរសាច់ប្រាក់ប៉ាន់ស្មាន ដែលបានបញ្ចុះតម្លៃតាមអត្រាការប្រាក់ប្រកបដោយប្រសិទ្ធិភាព ("EIR")។ ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុ មានអត្រាការប្រាក់ប្រែប្រួល អត្រាចុះតម្លៃសម្រាប់វាស់វែងការខាតបង់បណ្តាលមកពីការថយចុះតម្លៃគឺជា អត្រាការប្រាក់ប្រកបដោយប្រសិទ្ធិភាពបច្ចុប្បន្នដែលបានកំណត់ក្នុងកិច្ចសន្យា។

ក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ប្រសិនបើបរិមាណនៃការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃមានការថយចុះ ហើយការថយចុះនោះអាចមានការពាក់ព័ន្ធចម្បងទៅនឹងព្រឹត្តិការណ៍មួយដែលបានកើតមានបន្ទាប់ពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់ អង្គភាពត្រូវធ្វើការកត់ត្រាបញ្ច្រាសមកវិញនូវការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយការកែគណនីសំវិធានធន។ ការកត់ត្រាបញ្ច្រាសនេះ មិនត្រូវធ្វើលើតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុ (បរិមាណនៃគណនីសំវិធានធនសុទ្ធ) ដែលលើសពីអ្វីដែលតម្លៃពិតគណនេយ្យមានដែលមានការថយចុះតម្លៃដែលមិនបានទទួលស្គាល់ពីមុន។ អង្គភាពត្រូវទទួលស្គាល់បរិមាណបញ្ច្រាស់ទាំងអស់ក្នុង ចំណេញឬខាតបង់ភ្លាមៗ។

***ការមិនទទួលស្គាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ***

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

ក្រុមហ៊ុននឹងមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុតែនៅពេលៈ

- សិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ ទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬ បានទូទាត់រួច ឬ
- ក្រុមហ៊ុនផ្ទេរទៅឱ្យភាគីផ្សេងទៀត នូវហានិភ័យនិងរង្វាន់កម្មសិទ្ធសំខាន់ៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- ទោះបីក្រុមហ៊ុនបានរក្សានូវហានិភ័យ និងរង្វាន់សំខាន់ៗ នៃកម្មសិទ្ធិសំខាន់ៗក៏ដោយក្រុមហ៊ុនបានផ្ទេរការគ្រប់គ្រងលើទ្រព្យសកម្មទាំងនោះទៅឱ្យភាគីផ្សេង ហើយភាគីផ្សេងមានលទ្ធភាពក្នុងការលក់ទ្រព្យសកម្មទាំងអស់ទៅឱ្យតតិយជនដែលមិនពាក់ព័ន្ធ ហើយ ភាគីផ្សេងនោះអាចអនុវត្តលទ្ធភាពជាឯកតោភាគី ដោយមិនចាំបាច់ដាក់លក្ខខណ្ឌបន្ថែមលើការផ្ទេរនោះទេ។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវ (ក) មិនទទួលស្គាល់ទ្រព្យសកម្ម និង (ខ) ទទួលស្គាល់ដាច់ដោយឡែកពីគ្នានូវសិទ្ធិនិងកាតព្វកិច្ច ដែលមានឬដែលបានបង្កើតឡើងនៅក្នុងការផ្ទេរ។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

***ការមិនទទួលស្គាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*ទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

ប្រសិនបើការផ្ទេរមិនបានបណ្តាលឱ្យមានការមិនទទួលស្គាល់ដោយសារតែ ក្រុមហ៊ុនបានរក្សានូវហានិភ័យនិងរង្វាន់កម្មសិទ្ធិសំខាន់ៗនៃទ្រព្យសកម្មដែលបានផ្ទេរ ហើយក្រុមហ៊ុនត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរនៅក្នុងទ្រព្យសកម្មទាំងមូល ហើយត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុសម្រាប់តម្លៃតបស្នងដែលទទួលបាន។ ទ្រព្យសម្បត្តិនិងបំណុលមិនត្រូវកាត់កងគ្នាឡើយ។ សម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ ក្រុមហ៊ុនត្រូវទទួលស្គាល់នូវ ចំណូលពីការផ្ទេរទ្រព្យសកម្ម និងទទួលស្គាល់នូវ ចំណាយនានាដែលកើតមានលើបំណុលហិរញ្ញវត្ថុ។

*បំណុលហិរញ្ញវត្ថុ*

បំណុលហិរញ្ញវត្ថុ មិនត្រូវបានទទួលស្គាល់នៅពេលដែលកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាត្រូវបានបំពេញ រំសាយចោល ឬ ផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយបំណុលហិរញ្ញវត្ថុផ្សេង ពីអ្នកផ្តល់ប្រាក់កម្ចីដូចគ្នាដោយមានលក្ខខណ្ឌចម្បងផ្សេងគ្នា ឬលក្ខខណ្ឌសំខាន់ៗ នៃបំណុលដែលមានស្រាប់ត្រូវបានកែប្រែ នោះការជំនួសនិងការកែប្រែទាំងនេះត្រូវបានចាត់ទុកជាការមិនទទួលស្គាល់នៃតម្លៃបំណុលហិរញ្ញវត្ថុដើម និងទទួលស្គាល់តែតម្លៃនៃបំណុលហិរញ្ញវត្ថុថ្មី ហើយភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃបំណុលហិរញ្ញវត្ថុណាមួយ នឹងត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ ឬខាត។

***សាច់ប្រាក់ និងសាច់ប្រាក់សមមូល***

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់សុទ្ធ និងសមមូលសាច់ប្រាក់រួមមានសាច់ប្រាក់ដែលមានក្នុងដៃ សមតុល្យបញ្ញើរជាមួយធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងទៀត រួមទាំងការវិនិយោគរយៈពេលខ្លីជាមួយនឹងកាលកំណត់បីខែ ឬក៏តិចជាងនេះ ដែលអាចបង្វិលជាសាច់ប្រាក់ ហើយ ប្រឈមនឹងហានិភ័យតិចក្នុងការផ្លាស់ប្តូរតម្លៃ។

***សាច់ប្រាក់បញ្ញើរជាមួយធនាគារផ្សេងៗ***

សាច់ប្រាក់បញ្ញើរជាមួយធនាគារផ្សេងទៀតត្រូវបានអនុវត្តតាមតម្លៃដើម។

***ប្រាក់បញ្ញើតាមតម្រូវការ***

ប្រាក់បញ្ញើតាមតម្រូវការ ត្រូវបានរក្សានៅធនាគារជាតិនៃកម្ពុជាដោយអនុលោមតាមច្បាប់ស្តីពីស្ថាប័នធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ហើយត្រូវបានកំណត់ដោយភាគរយនៃដើមទុនភាគហ៊ុនអប្បបរមានិងប្រាក់បញ្ញើរបស់អតិថិជនតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

***ប្រាក់កម្ចី និងបុរេប្រទានដល់អតិថិជន***

ប្រាក់កម្ចីនិងបុរេប្រទានដល់អតិថិជនត្រូវបានទទួលស្គាល់ ជាដំបូងក្នុងតម្លៃប្រតិបត្តិការ (រាប់បញ្ចូលទាំងថ្លៃដើមប្រតិបត្តិការ) និងវាស់វែងជាបន្តបន្ទាប់ ដោយចំណាយរំលស់ដោយប្រើវិធីសាស្ត្រ ការប្រាក់ប្រកប ដោយប្រសិទ្ធភាព។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*ប្រាក់កម្ចី និងបុរេប្រទានដល់អតិថិជន* (តពីទំព័រមុន)

នៅចុងការិយច្ឆេទរបស់របាយការណ៍នីមួយៗ តម្លៃយោងនៃប្រាក់កម្ចីនិងបុរេប្រទានអតិថិជនត្រូវបានពិនិត្យឡើងវិញ ដើម្បីកំណត់ថាតើមានភ័ស្តុតាងជាក់ស្តែងណាមួយនៃការអន់ថយឬអត់។ ប្រសិនបើមានភ័ស្តុតាងជាក់ស្តែងនៃការចុះខ្សោយ ការខាតបង់លើឱនភាពតម្លៃត្រូវបានទទួលស្គាល់ភ្លាមៗ ក្នុងប្រាក់ចំណេញ ឬការបាត់បង់។

ការខាតបង់លើឱនភាពនៃតម្លៃគឺជាភាពខុសគ្នារវាងតម្លៃយោងឥណទាន និងបុរេប្រទាន និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ក្នុងអត្រាអប្បហារការប្រាក់ ដ៏មានប្រសិទ្ធភាពសម្រាប់ភាពដើមរបស់ទ្រព្យសម្បត្តិ។

ភស្តុតាងដែលបញ្ជាក់ពីភាពអន់ថយ រួមមានទិន្នន័យដែលអាចអង្កេតបានដែលបានមកពីការយកចិត្តទុកដាក់របស់អ្នកគ្រប់គ្រងអំពីព្រឹត្តិការណ៍បាត់បង់ដូចខាងក្រោម:

(ក) ការលំបាកផ្នែកហិរញ្ញវត្ថុសំខាន់ៗរបស់អ្នកខ្ចី

(ខ) ការបំពានលើកិច្ចសន្យា ដូចជាការខកខាន ឬការខកខានលើការប្រាក់ ឬការទូទាត់ប្រាក់ដើម។

(គ) ភាពទៀវូចដែលអ្នកខ្ចីអាចនឹងក្ស័យធន

(ឃ) ទិន្នន័យដែលអាចអង្កេតបាន បង្ហាញថាមានការថយចុះ ដែលអាចវាស់វែងបាននៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលបានប៉ាន់ប្រមាណពីក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យទាំងនោះ ទោះបីជាការថយចុះមិនទាន់ត្រូវបានកំណត់ជាមួយ នឹងទ្រព្យសកម្មនីមួយៗ នៅក្នុងក្រុម ដូចជាស្ថានភាពសេដ្ឋកិច្ចថ្នាក់ជាតិ ឬមូលដ្ឋានមិនល្អ ឬការផ្លាស់ប្តូរមិនល្អនៅក្នុងលក្ខខណ្ឌវិស័យខុសៗគ្នាក៏ដោយ។

***ប្រាក់កម្ចី និងបុរេប្រទានដល់អតិថិជន***

ប្រាក់កម្ចីនិងបុរេប្រទានដល់អតិថិជនត្រូវបានដាក់ជាក្រុម ដោយផ្អែកលើលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា។

*ការកត់ត្រាបញ្ច្រាសមកវិញនៃការថយចុះតម្លៃ*

ក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ប្រសិនបើបរិមាណនៃការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃមានការថយចុះ ហើយការថយចុះនោះអាចមានការពាក់ព័ន្ធចម្បងទៅនឹងព្រឹត្តិការណ៍មួយដែលបានកើតមានបន្ទាប់ពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់ អង្គភាពត្រូវធ្វើការកត់ត្រាបញ្ច្រាសមកវិញនូវការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយការកែគណនីសំវិធានធន។ ការកត់ត្រាបញ្ច្រាសនេះ មិនត្រូវធ្វើលើតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុ (បរិមាណនៃគណនីសំវិធានធនសុទ្ធ) ដែលលើសពីអ្វីដែលតម្លៃពិតគណនេយ្យមានដែលមានការថយចុះតម្លៃដែលមិនបានទទួលស្គាល់ពីមុន។ អង្គភាពត្រូវទទួលស្គាល់បរិមាណបញ្ច្រាស់ទាំងអស់ក្នុង ចំណេញឬខាតបង់ភ្លាមៗ។

## 2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*ទុនបម្រុងបទប្បញ្ញត្តិ*

ទុនបម្រុងបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នារវាងសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកដោយអនុលោមតាម CIFRS for SMEs និងបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគាជាតិ នៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីចំណាត់ថ្នាក់នៃហានិភ័យឥណទាន និងការផ្តល់សំវិធានធនសម្រាប់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុ។

ប្រកាសតម្រូវឱ្យ គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុចាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាប្រាំថ្នាក់ និងផ្តល់សំវិធានធនទូទៅ និងជាក់លាក់ដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

| *ចំណាត់ថ្នាក់* | *ចំនួនថ្ងៃលើសកាលកំណត់* | *អត្រាសំវិធានធន* |
|---|---|---|
| ស្តង់ដារ | 0 ថ្ងៃដល់ 14 ថ្ងៃ (រយៈពេលខ្លី) | |
| | 0 ថ្ងៃដល់ 29 ថ្ងៃ (រយៈពេលវែង) | 1% |
| ឃ្លាំមើល | 15 ថ្ងៃដល់ 30 ថ្ងៃ (រយៈពេលខ្លី) | |
| | 30 ថ្ងៃដល់ 89 ថ្ងៃ (រយៈពេលវែង) | 3% |
| ក្រោមស្តង់ដារ | 31 ថ្ងៃដល់ 60 ថ្ងៃ (រយៈពេលខ្លី) | |
| | 90 ថ្ងៃដល់ 179 ថ្ងៃ (រយៈពេលវែង) | 20% |
| សង្ស័យ | 61 ថ្ងៃដល់ 90 ថ្ងៃ (រយៈពេលខ្លី) | |
| | 180 ថ្ងៃដល់ 359 ថ្ងៃ (រយៈពេលវែង) | 50% |
| បាត់បង់ | ចាប់ពី 91 ថ្ងៃ (រយៈពេលខ្លី) | |
| | 360 ថ្ងៃឬ ច្រើនជាង ថ្ងៃឬ (រយៈពេលវែង) | 100% |

ស្ថាប័នត្រូវប្រៀបធៀបសំវិធានធនតាមបទប្បញ្ញត្តិ ជាមួយនឹង សំវិធានធនដែលបានគណនាស្របតាម CIFRS for SMEs ហើយកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ទាបជាង សំវិធានធនដែលបានគណនាស្របតាម CIFRS for SMEs គ្រឹះស្ថានធនាគារកត់ត្រាសំវិធានធនតាមការគណនាស្របតាម CIFRS for SMEs

(ii) ក្នុងករណី សំវិធានធនតាមបទប្បញ្ញត្តិ ខ្ពស់ជាង សំវិធានធនដែលបានគណនាតាម CIFRS for SMEs គ្រឹះស្ថានកត់ត្រាសំវិធានធនដែលបានគណនាស្របតាម CIFRS for SMEs និងផ្ទេរភាពខុសគ្នាពីគណនីប្រាក់ចំណេញដែលបានរក្សាទុក ទៅគណនីទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*កម្ចី*

ប្រាក់កម្ចី ត្រូវបានទទួលស្គាល់ដំបូងតាមតំលៃទីផ្សារ ដោយដកចំណាយប្រតិបត្តិការផ្សេងៗ ដែលបានកើតឡើង។ បន្ទាប់ពីបានទទួលស្គាល់នូវតំលៃទីផ្សារ ប្រាក់កម្ចីដែលមានការប្រាក់ត្រូវបានវាស់វែង ដោយវាស់វែងតាមវិធីរំលស់ប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ភាពលំអៀងណាមួយរវាងសាច់ប្រាក់កម្ចីដែលបានទទួល (ដកចំណាយប្រតិបត្តិការផ្សេងៗ) និងតម្លៃរំដោះត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលពេញលេញ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាពលើរយៈពេលនៃប្រាក់កម្ចីនោះ។ សម្រាប់កម្ចីដែលមានអត្រាការប្រាក់ប្រែប្រួល វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ត្រូវបានគណនាដោយផ្អែកលើលំហូរសាច់ប្រាក់ដែលបានកែសម្រួលតាមការរំពឹងទុក នៅរាល់កាលបរិច្ឆេទរបាយការណ៍។

*អចលនទ្រព្យ និងបរិក្ខារ*

អចលនទ្រព្យ និងហាត្ថបករណ៍ត្រូវបានថែងតាមតម្លៃដើមដោយមិនរាប់បញ្ចូលសេវាកម្មប្រចាំថ្ងៃ ដកនឹងការរំលស់បង្គរនិងសំវិធានធនលើឱនភាពនៃតម្លៃ(បើមាន)។ ការផ្លាស់ប្តូរនៅក្នុងអាយុកាលប្រើប្រាស់ត្រូវបានរាប់បញ្ចូលដោយការផ្លាស់ប្តូររយៈពេលរំលស់ ឬវិធីសាស្ត្រដែលសមស្រប និងចាត់ទុកជាការផ្លាស់ប្តូរតាមការប៉ាន់ប្រមាណរបស់គណនេយ្យ។

អចលនទ្រព្យ និងហាត្ថបករណ៍ត្រូវបានកត់តាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃ បើមាន។ ថ្លៃដើមនៃអចលនទ្រព្យ និងហាត្ថបករណ៍រួមមានថ្លៃទិញ និងថ្លៃដើមដែលអាចបញ្ជាក់ដោយផ្ទាល់ក្នុងការនាំយកទ្រព្យនោះទៅក្នុងស្ថានភាពការងារ និងទីតាំងរបស់វាសម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។ នៅពេលដែលធាតុនៃអចលនទ្រព្យ និងហាត្ថបករណ៍មានសមាសធាតុសំខាន់ៗ មានអាយុកាលប្រើប្រាស់ខុសៗគ្នា សមាសធាតុទាំងនោះត្រូវបានចាត់ទុកថាជារបស់ដាច់ដោយឡែកពីគ្នានៃទ្រព្យសម្បត្តិនិងបរិក្ខារ។

ការចំណាយជាបន្តបន្ទាប់ទាក់ទងនឹងធាតុនៃអចលនទ្រព្យ និងហាត្ថបករណ៍ដែលត្រូវបានគេទទួលស្គាល់រួចហើយត្រូវបានបូកបន្ថែមទៅនឹងចំនួនទឹកប្រាក់យោងនៃទ្រព្យសកម្ម នៅពេលដែលភាពដែលអាចមានផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត លើសពីបទដ្ឋាននៃការវាយតម្លៃពីដំបូងនៃការអនុវត្តទ្រព្យសម្បត្តិដែលមានស្រាប់នឹងហូរចូលទៅក្រុមហ៊ុន។ រាល់ការចំណាយជាបន្តបន្ទាប់ផ្សេងៗ ទៀតត្រូវបានទទួលស្គាល់ថាជាការចំណាយក្នុងរយៈពេលដែលវាត្រូវបានចំណាយ។

ចំណេញ ឬខាតដែលកើតឡើងពីការចូលនិវត្តន៍ ឬការជំរះធាតុនៃអចលនទ្រព្យ និងហាត្ថបករណ៍ត្រូវបានកំណត់ថាជាភាពខុសគ្នារវាងចំណូលសុទ្ធនៃការជំរះធាតុដែលបានប៉ាន់ស្មាន នឹងចំនួនទឹកប្រាក់យោងក្នុងបញ្ជី នៃទ្រព្យសកម្មហើយត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញឬខាតបង់នៅកាលបរិច្ឆេទចូលនិវត្តន៍ ឬជំរះបញ្ជី។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*អចលនទ្រព្យ និងបរិក្ខារ* (តពីទំព័រមុន)

ការរំលស់ ត្រូវបានគណនាតាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាននៃទ្រព្យសកម្មដោយអនុវត្តអត្រារំលស់ដូចខាងក្រោម៖

ការកែលម្អទ្រព្យជួល រយៈពេលណាមួយដែលខ្លីជាងរយៈពេលជួល និងអាយុកាលសេដ្ឋកិច្ចរបស់វា

| | |
|---|---|
| ឧបករណ៍កំព្យូទ័រ | 2-4ឆ្នាំ |
| គ្រឿងបរិក្ខារការិយាល័យ | 4ឆ្នាំ |
| យានយន្ត | 4ឆ្នាំ |

អចលនទ្រព្យ និងបរិក្ខារដែលបានធ្វើការរំលស់ពេញលេញត្រូវបានរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ត្រូវបានជំរះចោល ឬដកចេញ។

ប្រសិនបើ មានការចង្អុលបង្ហាញថាមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៃអត្រារំលស់អាយុកាលប្រើប្រាស់ឬតម្លៃនៅសល់នៃទ្រព្យសកម្ម នោះការរំលស់នៃទ្រព្យសម្បត្តិនោះត្រូវបានកែលម្អដោយរំពឹងទុកដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកថ្មី។

*កម្មវិធីកុំព្យូទ័រ*

កម្មវិធីកុំព្យូទ័រ ត្រូវបានបង្ហាញជាថ្លៃដើមដោយដកចេញនូវការដករំលស់បង្គរ និងសំវិធានធន លើការស្រុតចុះតម្លៃ (បើមាន)។ វាត្រូវបានរំលស់តាមវិធីសាស្ត្ររំលស់ថេរ តាមអាយុកាល3-4ឆ្នាំ។ ប្រសិនបើ មានការចង្អុលបង្ហាញណាមួយដែលមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៃអត្រារំលស់អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់នៃកម្មវិធីកុំព្យូទ័រនោះ ការធ្វើរំលស់លើកម្មវិធីកុំព្យូទ័រ នឹងត្រូវបានកែសំរួល ដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកដែលកើតមានជាថ្មី។

*ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

នាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ទ្រព្យនិងបរិក្ខារ និងកម្មវិធីកុំព្យូទ័រត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីកំណត់ពីសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យទាំងនោះមានការធ្លាក់ចុះតម្លៃ។ ប្រសិនបើមានសញ្ញាណណាមួយបង្ហាញពីការធ្លាក់ចុះនូវតម្លៃ ទឹកប្រាក់ដែលអាចស្រង់មកវិញនៃទ្រព្យសកម្មនោះ (ឬក្រុមនៃទ្រព្យសកម្មដែលពាក់ព័ន្ធ) ត្រូវបានប៉ាន់ស្មាន និងប្រៀបធៀបនឹងតម្លៃពិតគណនេយ្យរបស់វា។ ប្រសិនបើចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញមានចំនួនទាបជាងនោះចំនួនដែលនៅក្នុងបញ្ជីត្រូវបានកាត់បន្ថយទៅជាចំនួនដែលអាចប្រមូលបានមកវិញ ហើយការខាតបង់លើឱនភាពតម្លៃត្រូវបានទទួលស្គាល់ភ្លាមៗ នៅក្នុងប្រាក់ចំណេញឬការបាត់បង់។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ* (តពីទំព័រមុន)

*ការគណនាចំនួនទឹកប្រាក់ដែលអាចប្រមូលបាន*

ចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញនៃក្រុមទ្រព្យសកម្មរយៈពេលវែង គឺជាតម្លៃធំជាងរវាងថ្លៃសមស្របដកតម្លៃលក់ និងតម្លៃប្រើប្រាស់របស់វា។ តម្លៃសមស្របដកថ្លៃលក់ គឺជាចំនួនទឹកប្រាក់ដែលទទួលបានពីការលក់ទ្រព្យសកម្ម ក្នុងប្រតិបត្តិការជំហោងដៃរវាងភាគីដែលមិនពាក់ព័ន្ធដកថ្លៃលក់ ។ ដើម្បីប៉ាន់ស្មានពីតម្លៃប្រើប្រាស់ លំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្នរបស់វា ដោយប្រើប្រាស់អត្រាអប្បហារ មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃលើតម្លៃពេលវេលា នៃសាច់ប្រាក់ ក្នុងទីផ្សារបច្ចុប្បន្ន ហើយនិងហានិភ័យជាក់លាក់ណាមួយរបស់ទ្រព្យសកម្មនោះ។ ចំពោះទ្រព្យសកម្ម ដែលមិនអាចបង្កើតលំហូរចូលសាច់ប្រាក់ឯករាជ្យបានច្រើននោះ ទឹកប្រាក់ដែលអាចស្រង់មកវិញត្រូវបានកំណត់ចំពោះផ្នែកបង្កើតសាច់ប្រាក់ដែលទ្រព្យសកម្មនោះស្ថិតនៅ។

*ការកត់ត្រាបញ្ច្រាសមកវិញនៃការថយចុះតម្លៃ*

ការខាតបង់ដោយសារការធ្លាក់ចុះតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាស់ត្រលប់វិញ ប្រសិនបើមានការប្រែប្រួលណាមួយលើការប៉ាន់ស្មានទឹកប្រាក់ដែលអាចស្រង់មកវិញនោះ ហើយនិងប្រសិនបើកាលៈទេសៈក្រោយមកទៀតមានភាពប្រសើរឡើង ព្រមទាំងមានភស្តុតាងដែលបង្ហាញថាកាលៈទេសៈដែលមានភាពប្រសើរឡើងនោះនៅតែមានបន្តទៅទៀត។

ការខាតបង់ដោយសារការធ្លាក់ចុះតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាស់ត្រលប់វិញតែក្នុងកម្រិតមួយដែលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនោះមិនលើសពីតម្លៃពិតគណនេយ្យដែលបានកំណត់ (បន្ទាប់ពីដកចេញនូវរំលស់) ប្រសិនបើមិនមានការទទួលស្គាល់ លើការខាតបង់ដោយសារការធ្លាក់ចុះតម្លៃពីមុននោះទេ។

***អត្ថប្រយោជន៍របស់និយោជិក***

*អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី*

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានបង្គរនៅក្នុងរយៈពេលហិរញ្ញវត្ថុ ដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ដោយនិយោជិករបស់ក្រុមហ៊ុន។

នៅឆ្នាំ2018 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសលេខ 443 ចុះថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 ស្តីពីការអនុវត្តន៍ការទូទាត់ប្រាក់បំណាច់អតីតភាពការងារសម្រាប់និយោជិកសហគ្រាសគ្រឹះស្ថាននិងអ្នកដែលទទួលបានការធានាការផ្តល់អោយដូចមានចែងក្នុងមាត្រា 89 (ថ្មី)។

## 2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*អត្ថប្រយោជន៍របស់និយោជិក* (តពីទំព័រមុន)

*អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី* (តពីទំព័រមុន)

យោងតាមការប្រកាសលេខ 42 ចុះថ្ងៃទី 22 ខែមីនា ឆ្នាំ 2019ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង់នេះត្រូវចាប់ផ្តើមបង់ចាប់ពីខែធ្នូ ឆ្នាំ2021 ហើយនិងជារៀងរាល់ខែមិថុនា និងខែធ្នូ ដូចមានចែងខាងក្រោម៖

- ស្មើនឹងបីថ្ងៃត្រូវបង់នៅខែធ្នូ
- ស្មើនឹងបីថ្ងៃត្រូវបង់នៅខែមិថុនា

ការបង់នេះមានកម្រិតអតិបរមាមិនលើសពី 6ខែ នៃប្រាក់ឈ្នួលជាមធ្យម នៅឆ្នាំនីមួយៗ។ និយោជិកនឹងមិនទទួលបានការទូទាត់ឡើយ ប្រសិនបើលាលែងពីការងារមុនថ្ងៃនៃការទូទាត់។

*ភតិសន្យា*

ការកំណត់ថាតើកិច្ចសន្យាមួយជាភតិសន្យា គឺឈរលើមូលដ្ឋាននៃខ្លឹមសាររបស់កិច្ចសន្យានាកាលបរិច្ឆេទចាប់ផ្តើមដំបូង ដែលថាតើការបំពេញលក្ខខណ្ឌនៃកិច្ចសន្យានោះអាស្រ័យទៅលើការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ណាមួយ ឬច្រើន ឬក៏កិច្ចសន្យានោះបានផ្ទេរសិទ្ធិដើម្បីប្រើប្រាស់នូវទ្រព្យសកម្មទាំងនោះឬទេ។

*ក្រុមហ៊ុនជាភតិក:*

ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្រ្តរំលស់ស្មើភាគសម្រាប់រយៈពេលនៃភតិសន្យា។

***ពន្ធលើប្រាក់ចំណូល***

*ពន្ធក្នុងគ្រា*

ចំណាយពន្ធលើប្រាក់ចំណេញ គឺជាផលបូករវាងពន្ធក្នុងគ្រាដែលត្រូវបង់ និងពន្ធពន្យារ។ ពន្ធក្នុងគ្រាដែលត្រូវបង់ ត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណេញជាប់ពន្ធនៅក្នុងឆ្នាំ។

ពន្ធពន្យារលើប្រាក់ចំណូល ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្រ្តទ្រព្យអកម្ម លើភាពខុសគ្នាបណ្តោះអាសន្ននាកាលបរិច្ឆេទរបាយការណ៍ រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ហើយនិងតម្លៃពិតគណនេយ្យសម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យអកម្ម ត្រូវបានទទួលស្គាល់លើលម្អៀងបណ្តោះអាសន្ន ដែលជាប់ពន្ធទាំងអស់ លើកលែងតែករណីដែល ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យអកម្ម កើតចេញពីការទទួលស្គាល់ដំបូងនៃកេរ្តិ៍ឈ្មោះអាជីវកម្ម ទ្រព្យសកម្ម ឬ ទ្រព្យអកម្ម នៅក្នុងប្រតិបត្តិការដែលមិនមែនជាការបញ្ចូលអាជីកម្មរួមគ្នា ហើយនិងមិនប៉ះពាល់ទៅលើប្រាក់ចំណេញគិតតាមគណនេយ្យ និងប្រាក់ចំណេញឬខាតគិតតាមច្បាប់ពន្ធ នៅពេលដែលប្រតិបត្តិការកើតឡើង។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***ពន្ធលើប្រាក់ចំណូល*** (តពីទំព័រមុន)

*ពន្ធក្នុងគ្រា* (តពីទំព័រមុន)

ពន្ធពន្យា លើប្រាក់ចំណេញជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់លើលម្អៀងបណ្តោះអាសន្នទាំងអស់ដែលអាចកាត់កងបានដូចជា ឥណទានពន្ធដែលមិនទាន់បានប្រើ និងការខាតពន្ធមិនទាន់បានប្រើ ក្នុងទំហំមួយដែលវាគឺអាចកើតឡើង ដែលប្រាក់ចំណេញជាប់ពន្ធនឹងមានគ្រប់គ្រាន់បើធៀបទៅនឹងលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ហើយឥណទានពន្ធដែលមិនទាន់បានប្រើ និងការខាតពន្ធមិនទាន់បានប្រើ អាចប្រើប្រាស់បាន លើកលែងតែករណីដែល ពន្ធពន្យាលើប្រាក់ចំណូលជាទ្រព្យសកម្ម កើតចេញពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬ ទ្រព្យអកម្មនៅក្នុងប្រតិបត្តិការដែលមិនមែនជាការបញ្ចូលលអាជីកម្មរួមគ្នា ហើយនិងមិនប៉ះពាល់ទៅលើប្រាក់ចំណេញគិតតាមគណនេយ្យនិងប្រាក់ចំណេញឬខាតគិតតាមច្បាប់ពន្ធ នៅពេលដែលប្រតិបត្តិការកើតឡើង។

តម្លៃពិតគណនេយ្យនៃពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនាចុងកាលបរិច្ឆេទរបាយការណ៍និមួយៗ ហើយត្រូវបន្ថយមកត្រឹមកម្រិតមួយដែល ប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ នឹងមានសម្រាប់ឱ្យចំនួនទាំងអស់ឬមួយផ្នែកនៃពន្ធពន្យារជាទ្រព្យសកម្មអាចត្រូវបានប្រើប្រាស់។

ពន្ធពន្យារលើប្រាក់ចំណូលត្រូវបាន គណនា តាមអត្រាពន្ធដែលត្រូវបានរំពឹងសម្រាប់អនុវត្តលើប្រាក់ចំណេញជាប់ពន្ធ (ខាតពន្ធ) នៃការិយបរិច្ឆេទដែលគេរំពឹងថា ពន្ធពន្យារលើប្រាក់ចំណូលដែលត្រូវទទួលស្គាល់ ឬពន្ធលើប្រាក់ចំណេញជាទ្រព្យអកម្មដែលត្រូវទូទាត់ ដោយផ្អែកលើអត្រាពន្ធដែលបានអនុម័ត ឬនឹងត្រូវអនុម័តនាចុងការិយបរិច្ឆេទ។

ពន្ធពន្យារជាទ្រព្យសកម្មដែលមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនាចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់ត្រឹមកម្រិតមួយដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត នឹងអាចអនុញ្ញាតអោយកាត់កងជាមួយពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្មដែលអាចទទួលបាន។

ការគិតពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាផ្អែកលើមូលដ្ឋាននៃអត្រាពន្ធ និងច្បាប់ដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តជាធរមានតាមកាលបរិច្ឆេទរបាយការណ៍នៅក្នុងបណ្តាប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណូលជាប់ពន្ធ។ គណៈគ្រប់គ្រងធ្វើការវាយតម្លៃយ៉ាងទៀងទាត់នូវជំហារដែលប្រកាន់យកនៅក្នុងលិខិតប្រកាសពន្ធ ទាក់ទងនឹងស្ថានភាពដែលបទបញ្ញត្តិស្តីពីពន្ធដារ ទទួលរងនូវការបកស្រាយផ្សេងៗ។ ច្បាប់នេះបង្កើតសំវិធានធនដែលបទប្បញ្ញត្តិដែលសមស្របតាមមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់ជូនអាជ្ញាធរពន្ធ។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***ពន្ធលើប្រាក់ចំណូល*** (តពីទំព័រមុន)

*ពន្ធពន្យារលើប្រាក់ចំណូល*

ពន្ធពន្យាលើប្រាក់ចំណេញជាទ្រព្យសកម្ម និងជាទ្រព្យអកម្មអាចត្រូវបានធ្វើការកាត់កងគ្នា ប្រសិនបើមានសិទ្ធិអនុវត្តស្របច្បាប់ ដើម្បីកាត់កងពន្ធពន្យារជាទ្រព្យសកម្មក្នុងគ្រាជាមួយនឹងពន្ធពន្យាជាទ្រព្យអកម្មក្នុងគ្រានិងពន្ធពន្យារលើប្រាក់ចំណូលទាក់ទងនឹងអង្គភាពជាប់ពន្ធតែមួយ និងអាជ្ញាធរពន្ធដារតែមួយ។

*បំណុលផ្សេងៗ*

បំណុលផ្សេងៗត្រូវបានចែងដោយថ្លៃដើមដែលតំណាងឱ្យតម្លៃទីផ្សារនៃការពិចារណាដែលរំពឹងថានឹងត្រូវបង់នាពេលអនាគតសម្រាប់ទំនិញនិងសេវាកម្មដែលបានទទួល។

***សំវិធានធន***

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្នជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាអាចទៅរួចដែលលំហូរចេញនៃធនធានសេដ្ឋកិច្ចដែលទទួលបានអត្ថប្រយោជន៍ នឹងត្រូវបានទាមទារដើម្បីដោះស្រាយកាតព្វកិច្ចហើយការប៉ាន់ប្រមាណដែលអាចទុកចិត្តបានអាចនឹងត្រូវបានធ្វើឡើង។

សំវិធានធនត្រូវបានពិនិត្យឡើងវិញនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ និងកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានបច្ចុប្បន្ន។ នៅពេលដែលផលប៉ះពាល់នៃតម្លៃសាច់ប្រាក់មានភាពជាសារវន្ត ចំនួនទឹកប្រាក់នៃសំវិធានធន គឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងថានឹងត្រូវបានទាមទារដើម្បីដោះស្រាយកាតព្វកិច្ច។

***យថាភាព***

បំណុលយថាហេតុ មិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមទេ ប៉ុន្តែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់នៅរបាយការណ៍ហិរញ្ញវត្ថុរួម លុះត្រាតែលទ្ធភាពនៃការហូរចេញនៃធនធានដែលរួមបញ្ចូលផលប្រយោជន៍សេដ្ឋកិច្ចគឺនៅឆ្ងាយ។ ទ្រព្យសកម្មយថាហេតុមិនត្រូវបានទទួលស្គាល់ទេ ប៉ុន្តែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ដើម្បីបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅពេលដែលលំហូរចូលនៃផលប្រយោជន៍សេដ្ឋកិច្ចអាចនឹងកើតមាន។

***អត្រាការប្រាក់មានប្រសិទ្ធភាព (EIR)***

អត្រាការប្រាក់មានប្រសិទ្ធិភាព (EIR) គឺជាអត្រាជាក់លាក់មួយដែលធ្វើអប្បហារលើសាច់ប្រាក់ទូទាត់ ឬសាច់ប្រាក់ទទួលប៉ាន់ស្មាន នាពេលអនាគតតាមរយៈពេល ដែលរំពឹងទុកនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ អោយស្មើរទៅនឹង ទឹកប្រាក់ដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ថ្លៃដើមរំលស់នៃបំណុលហិរញ្ញវត្ថុ។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*អត្រាការប្រាក់មានប្រសិទ្ធភាព (EIR)* (តពីទំព័រមុន)

នៅពេលគណនាអត្រាការប្រាក់ដែលមានប្រសិទ្ធិភាព ក្រុមហ៊ុនប៉ាន់ប្រមាណលំហូរសាច់ប្រាក់ដែលរំពឹងទុកដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនគិតពីឥណទានបាត់បង់ដែលរំពឹងទុក។ ការគណនារាប់បញ្ចូលទាំងថ្លៃ និងចំណុចទាំងអស់ដែលបានបង់ ឬទទួលបានរវាងភាគីនៃកិច្ចសន្យាដែលជាផ្នែកសំខាន់នៃអត្រាការប្រាក់ប្រសិទ្ធភាព តម្លៃប្រតិបត្តិការ និងថ្លៃធានារ៉ាប់រងឬ តម្លៃអប្បហារដទៃទៀត។

ថ្លៃដើមប្រតិបត្តិការ គឺជាចំណាយបន្ថែមដែលត្រូវបានបង្កឡើងដោយផ្ទាល់ ទៅនឹងការទិញយក ដកចេញ ឬ ជំរះចោលទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ។ ចំណាយកើនឡើងគឺជាតម្លៃមួយដែលនឹងមិនត្រូវបានកើតឡើង ប្រសិនបើអង្គភាពមិនបានទិញយក ដកចេញ ឬជំរះចោលឧបករណ៍ហិរញ្ញវត្ថុ។

*ការទទួលស្គាល់ចំណូល និង ចំណាយ*

ចំណូលការប្រាក់គឺបានមកពីប្រាក់កម្ចី និងបុរេប្រទានទៅកាន់អតិថិជន និង សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា និង ធនាគារដទៃទៀត។ ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្រ្តការប្រាក់ដែលមានប្រសិទ្ធិភាពដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ រួមបញ្ចូលទាំងការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់ដោយចំណាយរំលស់។

ចំណាយការប្រាក់លើប្រាក់កម្ចីក៏ត្រូវបានគណនាដោយប្រើវិធីសាស្រ្ត EIR សម្រាប់បំណុលហិរញ្ញវត្ថុទាំងអស់ដែលត្រូវបានគិតតាមតម្លៃរំលស់។ ចំណាយការប្រាក់ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ រួមបញ្ចូលទាំងការប្រាក់លើទ្រព្យអកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់ដោយចំណាយរំលស់។

*ភាគីពាក់ព័ន្ធ*

សហគ្រាស និងបុគ្គលដែលគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលតាមរយៈអន្តរការីមួយ ឬច្រើនត្រូវបានគ្រប់គ្រងដោយ ឬស្ថិតក្រោមការគ្រប់គ្រងរួមជាមួយក្រុមហ៊ុន ដោយរួមបញ្ចូលទាំងការកាន់កាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀតដែលជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ សហការីនិងបុគ្គលដែលមានកម្មសិទ្ធលើផលប្រយោជន៍ ដោយប្រយោលលើសិទ្ធិក្នុងការបោះឆ្នោត នៃក្រុមអ្នកគ្រប់គ្រងដែលផ្តល់ឱ្យពួកគេនូវឥទ្ធិពលយ៉ាងសំខាន់ទៅលើសហគ្រាស បុគ្គលិកគ្រប់គ្រងសំខាន់ៗ រួមមាននាយក និងមន្ត្រីក្រុមហ៊ុននិងសមាជិកគ្រួសារជិតស្និទ្ធរបស់បុគ្គលទាំងនេះ និងក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយ បុគ្គលទាំងនេះក៏បង្កើតជាភាគីពាក់ព័ន្ធផងដែរ។ ក្នុងការពិចារណាលើទំនាក់ទំនងរបស់អង្គភាពនីមួយៗ ដែលអាចកើតមានការយកចិត្តទុកដាក់ ត្រូវបានផ្តោតទៅលើខ្លឹមសារនៃទំនាក់ទំនងហើយមិនត្រឹមតែជាទម្រង់ស្របច្បាប់ប៉ុណ្ណោះទេ។

## 3. ការផ្ទូរផ្គត់រវាង GAAP និង ការបង្ហាញថ្មីរបស់ CIFRS for SMEs

នៅក្នុងតារាងខាងក្រោមមូលធនដែលបានកំណត់ស្របតាមស្តង់ដារ CIFRS for SMEs ត្រូវបានផ្ទូរផ្គង់ជាមួយនឹងមូលធនដែលបានកំណត់ស្របតាម GAAPពីមុន នៅថ្ងៃទី1 ខែមករា ឆ្នាំ2018 (កាលបរិច្ឆេទផ្លាស់ប្តូរទៅតាមស្តង់ដារ CIFRS for SMEs) និងថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 (ចុងបញ្ចប់នៃកាលបរិច្ឆេទដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរិញ្ញវត្ថុស្ថិតនៅក្រោមការរៀបចំស្របតាមស្តង់ដា GAAP ពីមុន)។

| | *កំណត់សម្គាល់* | *ថ្ងៃទី1 ខែមករា ឆ្នាំ2018* | | | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018* | | | |
|---|---|---|---|---|---|---|---|---|---|
| | | *GAAP ពីមុន* | *ចំណាត់ថ្នាក់ឡើងវិញ* | *ការវាស់វែងឡើងវិញ* | *CIFRS for SMEs* | *GAAP ពីមុន* | *ចំណាត់ថ្នាក់ឡើងវិញ* | *ការវាស់វែងឡើងវិញ* | *CIFRS for SMEs* |
| | | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ទ្រព្យសកម្ម** | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | | 148,494 | - | - | 148,494 | 186,706 | - | - | 186,706 |
| សមតុល្យនៅធនាគារជាតិកម្ពុជា | | 105,833 | - | - | 105,833 | 106,593 | - | - | 106,593 |
| សមតុល្យនៅធនាគារដទៃ | (i) | 26,951 | - | - | 26,951 | 662,566 | | 6,693 | 669,259 |
| ប្រាក់កម្ចី និង បុរេប្រទាន | (ii) | 7,592,198 | 6,713 | (38,502) | 7,560,409 | 10,061,797 | (44,655) | 102,163 | 10,119,305 |
| ទ្រព្យសកម្មផ្សេងទៀត | (iii) | 122,452 | (104,484) | 35,737 | 53,705 | 155,088 | (131,385) | 45,973 | 69,676 |
| អចលនទ្រព្យ និងឧបត្ថករណ៍ | | 59,938 | - | - | 59,938 | 30,205 | - | - | 30,205 |
| ទ្រព្យសកម្មអរូបី | | 43,442 | - | - | 43,442 | 31,085 | - | - | 31,085 |
| ពន្ធពន្យាជាទ្រព្យសកម្ម | | 30,448 | - | - | 30,448 | 63,103 | - | - | 63,103 |
| **ទ្រព្យសកម្មសរុប** | | **8,129,756** | **(97,771)** | **(2,765)** | **8,029,220** | **11,297,143** | **(176,040)** | **154,829** | **11,275,932** |

## **កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 3. **ការផ្ទៀងផ្ទាត់រវាង** GAAP **និង ការបង្ហាញថ្មីរបស់** CIFRS for SMEs (តពីទំព័រមុន)

| | *កំណត់សម្គាល់* | *ថ្ងៃទី1 ខែមករា ឆ្នាំ2018* | | | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018* | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | *GAAP ពីមុន* | *ចំណាត់ថ្នាក់ឡើងវិញ* | *ការវាស់វែងឡើងវិញ* | *CIFRS for SMEs* | *GAAP ពីមុន* | *ចំណាត់ថ្នាក់ឡើងវិញ* | *ការវាស់វែងឡើងវិញ* | *ការរាយការណ៍ឡើងវិញ* | *CIFRS for SMEs* |
| | | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក (កំណត់សម្គាល់លេខ24)* | *ដុល្លារអាមេរិក* |
| **មូលធន និង បំណុល** | | | | | | | | | | |
| **បំណុល** | | | | | | | | | | |
| ពន្ធលើប្រាក់ចំណេញដែលត្រូវបង់ | | 52,873 | - | - | 52,873 | 88,021 | - | - | (32,655) | 55,366 |
| ប្រាក់កម្ចី | (iv) | 5,318,975 | 26,262 | - | 5,345,237 | 8,089,394 | 101,304 | - | - | 8,190,698 |
| បំណុលផ្សេងៗ | (v) | 156,438 | (124,033) | - | 32,405 | 371,699 | (277,344) | - | - | 94,355 |
| **បំណុលសរុប** | | **5,528,286** | **(97,771)** | **-** | **5,430,515** | **8,549,114** | **(176,040)** | **-** | **(32,655)** | **8,340,419** |
| **មូលធន** | | | | | | | | | | |
| ដើមទុន | | 2,103,000 | - | - | 2,103,000 | 2,103,000 | - | - | - | 2,103,000 |
| ប្រាក់ចំណេញរក្សាទុក | (vii) | 498,470 | - | (2,765) | 495,705 | 645,029 | (90,987) | 154,829 | 32,655 | 741,526 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | (viii) | - | - | - | - | - | 90,987 | - | - | 90,987 |
| **មូលធនសរុប** | | **2,601,470** | **-** | **(2,765)** | **2,598,705** | **2,748,029** | **-** | **154,829** | **32,655** | **2,935,513** |
| **មូលធន និង បំណុលសរុប** | | **8,129,756** | **(97,771)** | **(2,765)** | **8,029,220** | **11,297,143** | **(176,040)** | **154,829** | **-** | **11,275,932** |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 3. ***ការផ្ទូរផ្តច់ទោខ*** GAAP ***និង ការបង្ហាញថ្មីរបស់*** CIFRS for SMEs (តពីទំព័រមុន)

តារាងខាងក្រោមពិពណ៌នាអំពីភាពខុសគ្នារវាងប្រាក់ចំណេញឬខាតដែលបានបង្ហាញតាម GAAPពីមុន និងចំនួនទឹកប្រាក់ដែលត្រូវបានបង្ហាញថ្មីតាម CIFRS for SMEs សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018៖

| | *កំណត់សម្គាល់* | *GAAP* | *ចំណាត់ថ្នាក់ឡើងវិញ* | *បង្ហាញឡើងវិញ* | *កែតម្រូវឡើងវិញ* | *CIFRS for SMEs* |
|---|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក (កំណត់សម្គាល់លេខ 24)* | *ដុល្លារអាមេរិក* |
| ចំណូលការប្រាក់ | (vi) | 1,532,335 | 111,700 | (115) | - | 1,643,920 |
| ចំណាយការប្រាក់ | | (482,965) | - | - | - | (482,965) |
| **ចំណូលការប្រាក់សុទ្ធ** | | **1,049,370** | **111,700** | **(115)** | **-** | **1,160,955** |
| ប្រាក់ចំណូលប្រតិបត្តិការផ្សេងទៀត | (vi) | 185,615 | (111,700) | - | - | 73,915 |
| **ចំណូលការប្រាក់សុទ្ធ** | | **1,234,985** | **-** | **(115)** | **-** | **1,234,870** |
| ចំណាយបុគ្គលិក | | (601,082) | - | - | - | (601,082) |
| ចំណាយរំលស់ | | (47,649) | - | - | - | (47,649) |
| ចំណាយទូទៅនិងរដ្ឋបាល | | (260,668) | - | - | - | (260,668) |
| សំវិធានធនសម្រាប់ការខាតបង់លើប្រាក់កម្ចីនិងបុរេប្រទានអតិថិជន | (vi) | (125,324) | - | 157,709 | - | 32,385 |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | | **200,262** | **-** | **157,594** | **-** | **357,856** |
| ចំណាយពន្ធលើប្រាក់ចំណូល | | (53,703) | - | - | 32,655 | (21,048) |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | | **146,559** | **-** | **157,594** | **32,655** | **336,808** |

### 3. ***ការផ្លាស់ប្តូរពី GAAP និង ការបង្ហាញថ្មីរបស់ CIFRS for SMEs*** (តពីទំព័រមុន)

***ការពន្យល់កំណត់សម្គាល់ពីការផ្លាស់ប្តូរ***

*(i) សមតុល្យជាមួយធនាគារដទៃ*

និយ័តកម្មដោយសារការផ្លាស់ប្តូរ បានធ្វើអោយតម្លៃយោងនៃសមតុល្យនៅធនាគារផ្សេងៗ កើនឡើងចំនួន 6,693 ដុល្លារអាមេរិក (នាថ្ងៃទី1 ខែមករា ឆ្នាំ 2018៖ គ្មាន)

*(ii) ឥណទាន និងបុរេប្រទានទៅអតិថិជន*

នាថ្ងៃទី1 ខែមករា ឆ្នាំ2018 ឥណទាន និងបុរេប្រទាន បានថយចុះចំនួន 31,789 ដុល្លារអាមេរិក (នាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2018៖ កើនឡើងចំនួន 57,508 ដុល្លារអាមេរិក) ដោយសារៈ

(ក). ការធ្វើចំណាត់ឡើងវិញនៃការប្រាក់បង្គរដែលនឹងត្រូវទទួល ចេញពីទ្រព្យសកម្មទៅឥណទាន និងបុរេប្រទាននូវចំនួន 104,484 ដុល្លារអាមេរិក (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018៖ 131,385 ដុល្លារអាមេរិក)

(ខ). ការធ្វើចំណាត់ឡើងវិញនៃកម្រៃដំណើរការឥណទានមិនទាន់ទទួលស្គាល់ ចេញពីបំណុលផ្សេងៗ ដែលធ្វើអោយឥណទាន និងបុរេប្រទាន ថយចុះចំនួន 97,771 ដុល្លារអាមេរិក (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018៖ 176,040 ដុល្លារអាមេរិក)

(គ) ការធ្វើនិយ័តកម្មបង្គរលើកម្រៃដំណើរការឥណទានមិនទាន់ទទួលស្គាល់ បានធ្វើអោយតម្លៃយោងរបស់ឥណទាននិងបុរេប្រទានកើនឡើងចំនួន 28,220 ដុល្លារអាមេរិក និង 17,879 ដុល្លារអាមេរិក នាថ្ងៃទី1 ខែមករា និង ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 រៀងគ្នា។ ផលប៉ះពាល់ពីការទទួលស្គាល់កម្រៃដំណើរការឥណទានតាមវិធីសាស្ត្រ EIR បានធ្វើអោយចំណូលការប្រាក់ថយចុះចំនួន 10,351 ដុល្លារអាមេរិក សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 និង

(ឃ) ការធ្វើនិយ័តកម្មបង្គរ លើសំវិធានធនសម្រាប់ការខាតបង់ឥណទាន បានធ្វើតម្លៃយោងរបស់ឥណទាន និងបុរេប្រទានថយចុះចំនួន 66,722 ដុល្លារអាមេរិក នាថ្ងៃទី1 ខែមករា ឆ្នាំ2018 ប៉ុន្តែ តម្លៃយោងរបស់វាបានកើនឡើងវិញចំនួន 84,294 ដុល្លារអាមេរិក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ។ ការកត់ត្រាបញ្ច្រាស់នៃសំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទានបានធ្វើអោយចំណាយសំវិធានធនលើការខាតបង់ឥណទាន និង បុរេប្រទាន សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ថយចុះចំនួន 151,016 ដុល្លារអាមេរិក។

*(iii) ទ្រព្យសកម្មផ្សេងៗ*

នាថ្ងៃទី1 ខែមករា ឆ្នាំ2018 ទ្រព្យសកម្មផ្សេងៗ ថយចុះចំនួន 68,747 ដុល្លារអាមេរិក (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ៖ 85,412 ដុល្លារអាមេរិក) ដោយសារៈ

(ក) ការចាត់ថ្នាក់នៃការប្រាក់បង្គរដែលត្រូវទទួល ពីទ្រព្យសកម្មផ្សេងៗ ទៅឥណទាននិងបុរេប្រទាន ដូចបានពន្យល់នៅចំណុច (ii) (ក) ខាងលើ។

3. ***ការផ្លាស់ប្តូរខាង* GAAP *និង ការបង្ហាញថ្មីរបស់* CIFRS for SMEs** (តពីទំព័រមុន)

*ការពន្យល់កំណត់សម្គាល់ពីការផ្លាស់ប្តូរ* (តពីទំព័រមុន)

*(iii) ទ្រព្យសកម្មផ្សេងៗ* (តពីទំព័រមុន)

(ខ) នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ទ្រព្យសកម្មផ្សេងៗ បានកើនឡើងចំនួន 45,973 ដុល្លារអាមេរិក ដោយសារតែការប្រាក់ព្យួរទុកចំនួន 35,737 ដុល្លារអាមេរិក ត្រូវបានកត់ត្រាបញ្ច្រាស់ទៅប្រាក់ចំណេញរក្សារទុកនាថ្ងៃទី1 ខែមករា ឆ្នាំ2018 និងការទទួលស្គាល់ការប្រាក់ព្យួរទុកចំនួន 10,236 ដុល្លារអាមេរិក ជាចំណូលការប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។

*(iv) កម្ចី*

នាថ្ងៃទី1 ខែមករា ឆ្នាំ2018 កម្ចីបានកើនឡើងចំនួន26,262 ដុល្លារអាមេរិក (នាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ2018៖ 101,304 ដុល្លារអាមេរិក) ពីព្រោះការប្រាក់បង្គរដែលត្រូវសង ត្រូវបានចាត់ថ្នាក់ពីបំណុលផ្សេងៗ ទៅគណនីកម្ចី។

*(v) បំណុលផ្សេងៗ*

នាថ្ងៃទី1 ខែមករា ឆ្នាំ2018 បំណុលផ្សេងៗ បានថយចុះចំនួន 124,033 ដុល្លារអាមេរិក (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018៖ 277,344 ដុល្លារអាមេរិក) ដូចបានបង្ហាញក្នុងចំណុច (ii) (ខ) និង(iv)។

*(vi) ផលប៉ះពាល់នៃរបាយការណ៍ចំណេញឬខាតសម្រាប់ដំណាច់ឆ្នាំ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018*

(ក).ចំណូលការប្រាក់កើនឡើងចំនួន111,858ដុល្លារអាមេរិក ដោយមានមូលហេតុដូចខាងក្រោម៖

- ផលប៉ះពាល់លើការប្រាក់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព
- ផលប៉ះពាល់សុទ្ធ ដោយសារបម្រែបម្រួលនៃចំណុច (ii) (គ) និង (iii) (ខ) ការធ្វើនិយ័តកម្មចំនួន 115ដុល្លារអាមេរិកក្នុងកាលបរិច្ឆេទនេះ

(ខ). ផលប៉ះពាល់នៃបម្រែបម្រួលសំវិធានធនឥណទាន និងបុរេប្រទាន និងសមតុល្យជាមួយធនាគារផ្សេងៗចំនួន 157,707 ដុល្លារអាមេរិក ដែលបានបង្ហាញក្នុងចំណុច (i) និង (ii) (ឃ)។

*(vii) ទុនបម្រុងតាមបទប្បញ្ញត្តិ*

ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងបទប្បញ្ញត្តិ គឺផ្អែកលើតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា *(កំណត់សម្គាល់លេខ 16)* ។

*(viii) ប្រាក់ចំណេញរក្សាទុក*

ផលប៉ះពាល់ដោយសារនិយ័តកម្មលើការផ្លាស់ប្តូរទៅ CIFRS for SMEs បានធ្វើអោយប្រាក់ចំណេញរក្សាទុកថយចុះចំនួន 2,765 ដុល្លារអាមេរិក នាថ្ងៃទី1 ខែមករា ឆ្នាំ2018 និង កើនឡើងចំនួន 154,829 ដុល្លារអាមេរិក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ហេតុដូចនេះ ចំណេញសុទ្ធបានកើនឡើងចំនួន157,594 សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។

### 4. ***ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត់.***

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនតម្រូវឱ្យ គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត់ ដែលប៉ះពាល់ដល់ចំនួនទឹកប្រាក់ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សំគាល់ដែលពាក់ព័ន្ធ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគណៈគ្រប់គ្រង បានធ្វើការប៉ាន់ស្មាននិងវិនិច្ឆ័យបានល្អបំផុត នូវចំនួនជាក់លាក់ដោយផ្តល់ការពិចារណាឱ្យបាន ម៉ត់ចត់ទៅលើភាពជាសារវន្ត។ ការវិនិច្ឆ័យ ការប៉ាន់ប្រមាណ និងការសន្មតដែលត្រូវបានប្រើនៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភ្ជាប់មកជាមួយ គឺផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រងលើ អង្គហេតុដែលពាក់ព័ន្ធ និងកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលជាក់ស្តែងអាចនឹង ខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។ មូលដ្ឋានការប៉ាន់ស្មាននិងការសន្មត់ត្រូវបានពិនិត្យឡើងវិញជា ប្រចាំ។ ការពិនិត្យឡើងវិញលើការប៉ាន់ប្រមាណតាមគណនេយ្យត្រូវបានទទួលស្គាល់ក្នុងកំឡុង ពេលដែលការប៉ាន់ប្រមាណ ត្រូវបានកែលសម្រួលនិងក្នុងកំឡុងពេលណាមួយដែលនឹងមាននា ពេលអនាគត។

*ក) ការវិនិច្ឆ័យសំខាន់ៗ*

នៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន គណៈគ្រប់គ្រង បានធ្វើការវិនិច្ឆ័យដូចខាងក្រោម ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើចំនួនទឹកប្រាក់ដែលត្រូវ បានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុះ

*ការកំណត់មុខងាររូបិយប័ណ្ណ*

ផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃកាលៈទេសៈដែលទាក់ទងនឹងក្រុមហ៊ុន មុខងាររូបិយប័ណ្ណរបស់ ក្រុមហ៊ុនត្រូវបានកំណត់ជាដុល្លារអាមេរិក។ ដុល្លារអាមេរិកគឺជារូបិយប័ណ្ណនៃស្ថានភាពសេដ្ឋកិច្ច ចម្បងដែលក្រុមហ៊ុនធ្វើក្នុងកិច្ចប្រតិបត្តិការ ហើយវាជារូបិយប័ណ្ណដែលជះឥទ្ធិពលជាចំបង ដល់ការលក់សេវាកម្មនិងថ្លៃដើមនៃការលក់សេវាកម្ម

*ភតិសន្យាប្រតិបត្តិការ - ក្រុមហ៊ុនជាអ្នកជួល*

ក្រុមហ៊ុនបានចុះកិច្ចសន្យាជួលអចលនៈទ្រព្យក្រោមកិច្ចសន្យាជួលប្រតិបត្តិការ ក្នុងនាមជា អ្នកជួល។ ក្រុមហ៊ុនបានកំណត់ដោយផ្អែកលើ ការវាយតម្លៃលើលក្ខខណ្ឌនានានៃភតិសន្យា ថាភតិបតី រក្សានូវរាល់ហានិភ័យ និងផលប្រយោជន៍សំខាន់ៗ នៃភាពជាម្ចាស់លើទ្រព្យសម្បត្តិ ទាំងនេះ។

*ខ) ការប៉ាន់ប្រមាណនិងការសន្មតគណនេយ្យសំខាន់ៗ*

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាននិងការសន្មតទាក់ទងនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មាន តាមគណនេយ្យកម្រស្មើនឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ប្រមាណនិងការសន្មត់ដែល មានហានិភ័យខ្ពស់ ក្នុងការបង្កឱ្យមានការកែសំរួល ជាសារវន្តទៅនឹងចំនួនទឹកប្រាក់យោងនៃ ទ្រព្យសម្បត្តិ និងបំណុលត្រូវបានពិភាក្សាដូចខាងក្រោមៈ

4. ***ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត់.*** (តពីទំព័រមុន)

*ខ) ការប៉ាន់ប្រមាណនិងការសន្មតគណនេយ្យសំខាន់ៗ* (តពីទំព័រមុន)

*ការប៉ាន់ប្រមាណសំវិធានធនសម្រាប់ការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន*

សំវិធានធនសម្រាប់អ៊ីមភែមិន ត្រូវបានរក្សារត្រឹមកម្រិតមួយដែលចាត់ទុកថាគ្រប់គ្រាន់សម្រាប់ប្រាក់ដែលនិងត្រូវទទួលបាន ប៉ុន្តែមិនអាចប្រមូលបាន។ កម្រិតនៃសំវិធានធន គឺផ្អែកលើស្ថានភាពនៃចំណូលអាចទទួលបាន បទពិសោធន៍ដែលធ្លាប់ប្រមូលបានពីមុន និងកត្តាផ្សេងទៀតដែលអាចប៉ះពាល់ដល់ការប្រមូល។ សំវិធានធនត្រូវបានបង្កើតឡើងដោយកត់ត្រាទៅក្នុងរបាយការណ៍លទ្ធផល ក្នុងទម្រង់ជាសំវិធានធានសម្រាប់ការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន ។

*ការប៉ាន់ប្រមាណអាយុកាលនៃការប្រើប្រាស់លើអចលនទ្រព្យ និងឧបត្ថកម្ម និងកម្មវិធីកុំព្យូទ័រ*

ក្រុមហ៊ុនប៉ាន់ប្រមាណលើអាយុកាលប្រើប្រាស់ ឬអាយុកាលសេដ្ឋកិច្ចនៃអចលនទ្រព្យ និងហាត្ថបករណ៍ និងកម្មវិធីកុំព្យូទ័រ របស់ខ្លួន ផ្អែកលើអាយុកាលរបស់ទ្រព្យសកម្មត្រូវបានគេរំពឹងថាអាចប្រើបាន។ ជារៀងរាល់ឆ្នាំក្រុមហ៊ុនពិនិត្យឡើងវិញនូវអាយុកាល ឬអាយុកាលសេដ្ឋកិច្ចនៃអចលនទ្រព្យ និងហាត្ថបករណ៍ និងកម្មវិធីកុំព្យូទ័រ ដោយផ្អែកលើកត្តាដែលរួមមាន ការប្រើប្រាស់ទ្រព្យសម្បត្តិ ការវាយតំលៃបច្ចេកទេសផ្ទៃក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យា បរិស្ថាននិងការប្រើប្រាស់ទ្រព្យសម្បត្តិ ដែលបានប៉ាន់ស្មានដោយព័ត៌មានទាក់ទងនឹងប្រភេទទ្រព្យសម្បត្តិនោះ។ វាអាចទៅរួចដែលលទ្ធផលនៃប្រតិបត្តិការនាពេលអនាគត អាចរងផលប៉ះពាល់ដោយការផ្លាស់ប្តូរការប៉ាន់ស្មានទាំងនេះដែលកើតឡើងដោយការផ្លាស់ប្តូរកត្តា ដែលបានលើកឡើង។ ការកាត់បន្ថយអាយុកាលប្រើប្រាស់ ឬអាយុកាលសេដ្ឋកិច្ចនៃអចលនទ្រព្យនិងហាត្ថបករណ៍ និង កម្មវិធីកុំព្យូទ័រ នឹងបង្កើនការរំលស់និងការចំណាយរំលស់និងការថយចុះនៃអចលនទ្រព្យ និងហាត្ថបករណ៍ និងកម្មវិធីកុំព្យូទ័រ។

*ពន្ធ*

ភាពមិនច្បាស់លាស់អាចកើតមាន ទាក់ទងទៅនឹងការបកស្រាយបទប្បញ្ញត្តិពន្ធ ការផ្លាស់ប្តូរច្បាប់ពន្ធ ចំនួននិងពេលវេលានៃប្រាក់ចំណេញដែលជាប់ពន្ធនាពេលអនាគត។ ប្រព័ន្ធពន្ធដារនៅកម្ពុជាត្រូវបានកំណត់លក្ខណៈដោយពន្ធជាច្រើន និងច្បាប់ផ្លាស់ប្តូរជាញឹកញាប់ដែលភាគច្រើនមិនច្បាស់លាស់ ចម្រូងចម្រាស់ និងអាស្រ័យលើការបកស្រាយ។ ភាពខុសគ្នាដែលកើតឡើងរវាងលទ្ធផលជាក់ស្តែង និងការសន្មត់ដែលបានធ្វើឡើង ឬការផ្លាស់ប្តូរនាពេលអនាគតចំពោះការសន្មត់បែបនេះអាចចាំបាច់ត្រូវការការ កែតម្រូវនាពេលអនាគតចំពោះចំណូល និងចំណាយពន្ធដែលបានកត់ត្រារួចហើយ។ ក្រុមហ៊ុនបង្កើតសំវិធានធនផ្អែកលើការប៉ាន់ស្មានសមហេតុផលចំពោះផលវិបាកដែលអាចកើតមាននៃការធ្វើសវនកម្មដោយអាជ្ញាធរពន្ធដារ។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 5. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងគោលបំណងរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមាន៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| សាច់ប្រាក់ក្នុងដៃ | 224,616 | 915,310 | 186,706 | 750,185 |
| គណនីចរន្តនៅធនាគារជាតិកម្ពុជា | 2,239 | 9,124 | 1,443 | 5,798 |
| សមតុល្យនៅធនាគារផ្សេងទៀត | 11,429 | 46,573 | 669,259 | 2,689,083 |
| | **238,284** | **971,007** | **857,408** | **3,445,066** |

សាច់ប្រាក់ក្នុងដៃរួមមាន៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ដុល្លារអាមេរិក | 184,159 | 750,448 | 162,266 | 651,985 |
| ខ្មែររៀល | 40,457 | 164,862 | 24,440 | 98,200 |
| | **224,616** | **915,310** | **186,706** | **750,185** |

## 6. សមតុល្យនៅធនាគារជាតិ នៃកម្ពុជា

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| បញ្ញើតាមច្បាប់ | 179,650 | 732,074 | 105,150 | 422,493 |
| គណនីចរន្ត | 2,239 | 9,124 | 1,443 | 5,798 |
| | **181,889** | **741,198** | **106,593** | **428,291** |

យោងតាមប្រកាសលេខ B7-00-06 ចុះថ្ងៃទី11 ខែមករា ឆ្នាំ2000 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នីមួយៗ តម្រូវអោយរក្សាទុកប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 5% នៃដើមទុនដែលបានចុះបញ្ជីជាមួយនឹងធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃ របស់ក្រុមហ៊ុនបានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកយកវិញបាន នៅពេលដែលក្រុមហ៊ុនសំរេចចិត្តឈប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 6. សមតុល្យនៅធនាគារជាតិ នៃកម្ពុជា (តពីទំព័រមុន)

ប្រាក់តម្កល់កាតព្វកិច្ច ទទួលបានអត្រាការប្រាក់ស្មើរនឹង 1/2 នៃអត្រាហិរញ្ញប្បទានរយៈពេល 6ខែ កំនត់ដោយធនាគារជាតិនៃកម្ពុជាសម្រាប់ប្រាក់ដម្កល់កាតព្វកិច្ចជាប្រាក់រៀលខ្មែរ រីឯប្រាក់តម្កល់កាតព្វកិច្ចជាប្រាក់ដុល្លារអាមេរិក ទទួលបានអត្រាការប្រាក់ស្មើរនឹង 3/8 នៃអត្រា SIBOR រយៈពេល6ខែ។

ប្រាក់តម្កល់កាតព្វកិច្ចនេះ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំពី 0.48% - 0.72% (2018៖ 0.08% - 0.20%)។ ចំពោះគណនីចរន្ត ដែលបានដាក់នៅ ធនាគារជាតិនៃកម្ពុជាមិនទទួលបាន នូវការប្រាក់នោះទេ។

## 7. សមតុល្យនៅធនាគារផ្សេងៗ

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* |
| ដុល្លារអាមេរិក | 10,442 | 42,551 | 662,772 | 2,663,018 |
| ខ្មែររៀល | 987 | 4,022 | 6,487 | 26,065 |
| | **11,429** | **46,573** | **669,259** | **2,689,083** |

សមតុល្យនៅធនាគារដទៃ តំណាងឱ្យគណនីចរន្ត ដែលពុំទទួលបានការប្រាក់ទេ (ឆ្នាំ 2018៖ 0.00% - 1.50% ក្នុងមួយឆ្នាំ) ។

## 8. ឥណទាន និងបុរេប្រទានទៅអតិថិជន

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| ឥណទានបុគ្គល | 12,768,869 | 52,033,141 | 10,015,847 | 40,243,673 |
| ឥណទានក្រុម | 33,047 | 134,667 | 19,980 | 80,280 |
| ឥណទានបុគ្គលិក | 351,962 | 1,434,245 | 298,821 | 1,200,663 |
| | **13,153,878** | **53,602,053** | **10,334,648** | **41,524,616** |
| ការប្រាក់បង្គរដែលត្រូវទទួល | 159,619 | 650,448 | 131,386 | 527,909 |
| កម្រៃលើដំណើរឥណទានដែលមិនទាន់សំរេចបាន | (218,543) | (890,563) | (158,172) | (635,536) |
| | **13,094,954** | **53,361,938** | **10,307,862** | **41,416,989** |
| សំវិធានធនសម្រាប់ការខាតបង់លើឥណទាននិងបុរេប្រទាន | (254,757) | (1,038,135) | (188,557) | (757,622) |
| **ឥណទាន និងបុរេប្រទានទៅអតិថិជន - សុទ្ធ** | **12,840,197** | **52,323,803** | **10,119,305** | **40,659,367** |

## 8. ឥណទាន និងបុរេប្រទានទៅអតិថិជន (តពីទំព័រមុន)

បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់លើឥណទាន និងបុរេប្រទានទៅអតិថិជនមានដូចខាងក្រោម៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2) (ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* |
| សមតុល្យដើមគ្រា | 188,557 | 768,370 | 220,942 | 891,943 |
| សំវិធានធនក្នុងគ្រា | 66,311 | 270,217 | (32,385) | (130,997) |
| ភាពខុសគ្នាដោយការប្រែសម្រួលអត្រាប្តូរប្រាក់បរិយប័ណ្ណ | (111) | (452) | - | (3,324) |
| **សមតុល្យចុងគ្រា** | **254,757** | **1,038,135** | **188,557** | **757,622** |

ចំពោះការវិភាគទៅលើឥណទាន និងបុរេប្រទានមានដូចខាងក្រោម៖

*ក. ការវិភាគតាមទ្រព្យបញ្ចាំ*

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| មានទ្រព្យធានា | 12,963,176 | 52,824,942 | 10,187,092 | 40,931,736 |
| គ្មានទ្រព្យធានា | 190,702 | 777,111 | 147,556 | 592,880 |
| **សរុបឥណទានដុល** | **13,153,878** | **53,602,053** | **10,334,648** | **41,524,616** |

*ខ. ការវិភាគតាមប្រភេទឧស្សាហកម្ម*

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| អាជីវកម្មគ្រួសារ | 10,772,035 | 43,896,043 | 7,851,112 | 31,545,768 |
| ពាណិជ្ជកម្ម | 1,177,946 | 4,800,130 | 1,212,943 | 4,873,605 |
| សេវាកម្ម | 563,522 | 2,296,352 | 564,583 | 2,268,494 |
| កសិកម្ម | 194,867 | 794,083 | 144,317 | 579,866 |
| ការដឹកជញ្ជូន | 166,792 | 679,677 | 148,173 | 595,359 |
| សាងសង់ | 87,882 | 358,119 | 85,349 | 342,932 |
| ផ្សេងៗ | 190,834 | 777,649 | 328,171 | 1,318,592 |
| **ឥណទានសរុប** | **13,153,878** | **53,602,053** | **10,334,648** | **41,524,616** |

## 8. ឥណទាន និងបុរេប្រទានទៅអតិថិជន (តពីទំព័រមុន)

ចំពោះការវិភាគទៅលើឥណទាន និងបុរេប្រទានមានដូចខាងក្រោម៖ (តពីទំព័រមុន)

*គ. វិភាគសំណុំឥណទានតាម និវាសនភាព សម្ព័ន្ធញាតិ និងហានិភ័យ មានដូចខាងក្រោម៖*

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **និវេសនភាព៖** | | | | |
| និវេសនជន | **13,153,878** | **53,602,053** | **10,334,648** | **41,524,616** |
| **តាមទំនាក់ទំនង៖** | | | | |
| ភាគីពាក់ព័ន្ធ | 93,011 | 379,020 | 298,821 | 1,200,663 |
| ភាគីមិនពាក់ព័ន្ធ | 13,060,867 | 53,223,033 | 10,035,827 | 40,323,953 |
| | **13,153,878** | **53,602,053** | **10,334,648** | **41,524,616** |
| **ហានិភ័យ៖** | | | | |
| មិនធំ | **13,153,878** | **53,602,053** | **10,334,648** | **41,524,616** |

*ឃ តាមអត្រាការប្រាក់*

| | *2019* | *2018* |
|---|---|---|
| ឥណទានបុគ្គល | 13.20% - 18.00% | 13.00% - 18.00% |
| ឥណទានក្រុម | 18.00% | 18.00% |
| ឥណទានបុគ្គលិក | 13.20% - 15.60% | 13.00% - 16.00% |

## 9. ទ្រព្យសកម្មផ្សេង

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ប្រាក់ដម្កល់ធានា | 35,346 | 144,035 | 34,560 | 138,862 |
| ចំណាយបង់មុន | 33,203 | 135,302 | 30,834 | 123,891 |
| ផ្សេងៗ | 6,818 | 27,784 | 4,282 | 17,205 |
| | **75,367** | **307,121** | **69,676** | **279,958** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 10. អចលនទ្រព្យ និងបរិក្ខារ

| | *ការកែលម្អទ្រព្យជួល* | *គ្រឿងបរិក្ខារការិយាល័យ* | *ឧបករណ៍កុំព្យូទ័រ* | *យានយន្ត* | *សរុប* |
|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2019 | 78,794 | 45,038 | 74,432 | 19,800 | 218,064 |
| បន្ថែម | 1,814 | 4,904 | 11,301 | - | 18,019 |
| ការលុបចេញពីបញ្ជីឬការលក់ | (1,020) | (874) | (4,135) | - | (6,029) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **79,588** | **49,068** | **81,598** | **19,800** | **230,054** |
| **ដកៈរំលស់បង្គរ** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2019 | 66,412 | 34,298 | 72,906 | 14,243 | 187,859 |
| បន្ថែមក្នុងឆ្នាំ | 6,813 | 6,144 | 4,329 | 3,853 | 21,139 |
| ការលុបចេញពីបញ្ជីឬការលក់ | (1,020) | (874) | (4,135) | - | (6,029) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **72,205** | **39,568** | **73,100** | **18,096** | **202,969** |
| **តម្លៃពិតគណនេយ្យ** | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **7,383** | **9,500** | **8,498** | **1,704** | **27,085** |
| ពាន់រៀល *(កំណត់សម្គាល់លេខ 2)* | **30,086** | **38,712** | **34,629** | **6,944** | **110,371** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 10. អចលនទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

| | *ការកែលម្អទ្រព្យជួល* | *គ្រឿងបរិក្ខារការិយាល័យ* | *ឧបករណ៍កុំព្យូទ័រ* | *យានយន្ត* | *សរុប* |
|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2018 | 76,319 | 41,954 | 74,432 | 19,800 | 212,505 |
| បន្ថែម | 2,475 | 3,084 | - | - | 5,559 |
| ការលុបចេញពីបញ្ជីឬការលក់ | - | - | - | - | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **78,794** | **45,038** | **74,432** | **19,800** | **218,064** |
| **ដកៈរំលស់បង្គរ** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2018 | 60,306 | 25,553 | 58,613 | 8,095 | 152,567 |
| បន្ថែមក្នុងឆ្នាំ | 6,106 | 8,745 | 14,293 | 6,148 | 35,292 |
| ការលុបចេញពីបញ្ជីឬការលក់ | - | - | - | - | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **66,412** | **34,298** | **72,906** | **14,243** | **187,859** |
| **តម្លៃពិតគណនេយ្យ** | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **12,382** | **10,740** | **1,526** | **5,557** | **30,205** |
| **ពាន់រៀល** *(កំណត់សម្គាល់លេខ 2)* | **49,752** | **43,153** | **6,131** | **22,328** | **121,364** |

## 11. កម្មវិធីកុំព្យូទ័រ

| | 2019 | 2018 |
|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **តម្លៃដើម** | | |
| នាថ្ងៃទី1 ខែមករា | 54,495 | 54,495 |
| ការទិញបន្ថែម | - | - |
| **នាថ្ងៃទី31 ខែធ្នូ** | **54,495** | **54,495** |
| **ដកៈរំលស់បង្គរ** | | |
| នាថ្ងៃទី1 ខែមករា | 23,410 | 11,053 |
| ការរំលស់ | 12,358 | 12,357 |
| **នាថ្ងៃទី31 ខែធ្នូ** | **35,768** | **23,410** |
| **តម្លៃពិតគណនេយ្យ** | | |
| **នាថ្ងៃទី31 ខែធ្នូ** | **18,727** | **31,085** |
| **ពាន់រៀល** *(កំណត់សម្គាល់លេខ 2)* | **76,313** | **124,900** |

## 12. ពន្ធលើប្រាក់ចំណូល

ផ្នែកនៃចំណាយពន្ធលើប្រាក់ចំណូលសម្រាប់ការិយបរិច្ឆេទនេះមានដូចខាងក្រោមៈ

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| ពន្ធក្នុងគ្រា | 102,234 | 414,252 | 53,703 | 217,229 |
| ពន្ធពន្យា | (8,521) | (34,527) | (32,655) | (132,090) |
| ចំណាយពន្ធលើប្រាក់ចំណូល | **93,713** | **379,725** | **21,048** | **85,139** |

### *12.1 ចំណាយពន្ធលើ ប្រាក់ចំណូលក្នុងគ្រា*

អនុលោមតាមបទប្បញ្ញត្តិស្តីពីពន្ធដារកម្ពុជា ពន្ធលើប្រាក់ចំណូលក្នុងគ្រាត្រូវបានគណនាខ្ពស់ជាងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំគុណនឹងអត្រាពន្ធ 20ភាគរយនៅកាលបរិច្ឆេទរបាយការណ៍ និងអត្រាពន្ធ 1 ភាគរយនៃចំណូល។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 12. **ពន្ធលើប្រាក់ចំណូល** (តពីទំព័រមុន)

### *12.1 ចំណាយពន្ធលើ ប្រាក់ចំណូលក្នុងគ្រា* (តពីទំព័រមុន)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណូល ដែលបានគណនាតាមអត្រាពន្ធតាមច្បាប់ទៅនឹងការចំណាយពន្ធលើប្រាក់ចំណូលបានបង្ហាញជាប្រាក់ចំណេញឬខាតបង់មានដូចខាងក្រោម៖

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| **ចំណេញមុនបង់ពន្ធ** | **396,566** | **1,606,885** | **357,856** | **1,447,528** |
| ពន្ធលើប្រាក់ចំណូលក្នុងគ្រាតាមបទប្បញ្ញត្តិ | 79,313 | 321,376 | 71,571 | 289,505 |
| ចំណាយដែលមិនអាចកាត់កងបាន | 14,400 | 58,349 | 13,651 | 55,218 |
| ភាពខុសគ្នាបណ្តោះអាសន្ន | - | - | (64,174) | (259,584) |
| **ចំណាយពន្ធលើប្រាក់ចំណេញ** | **93,713** | **379,725** | **21,048** | **85,139** |

លិខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនត្រូវឆ្លងកាត់ការត្រួតពិនិត្យជាទៀងទាត់ដោយ អាជ្ញាធរពន្ធដារ ដោយសារការអនុវត្តច្បាប់ពន្ធនិងបទប្បញ្ញត្តិចំពោះប្រតិបត្តិការជាច្រើនប្រភេទងាយនឹងមានការបកស្រាយខុសគ្នា ចំនួនទឹកប្រាក់ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរនៅពេលក្រោយតាមការកំណត់ចុងក្រោយរបស់អាជ្ញាធរពន្ធ។

### *12.2 បំណុលពន្ធ*

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| សមតុល្យដើមគ្រា | 55,366 | 222,461 | 52,873 | 213,448 |
| ចំណាយពន្ធក្នុងឆ្នាំ | 102,233 | 414,248 | 53,703 | 217,229 |
| ការទូទាត់ពន្ធ | (64,978) | (263,291) | (51,210) | (207,144) |
| ភាពខុសគ្នាលើអត្រាប្តូរប្រាក់ | - | 4,014 | - | (1,072) |
| **សមតុល្យចុងគ្រា** | **92,621** | **377,432** | **55,366** | **222,461** |

## 12. ពន្ធលើប្រាក់ចំណូល (តពីទំព័រមុន)

### *12.3. ពន្ធពន្យាជាទ្រព្យសកម្មសុទ្ធ*

ពន្ធពន្យាជាទ្រព្យសកម្ម ***និង***បំណុល នៅក្នុងការិបរិច្ឆេទនេះមានដូចខាងក្រោម៖

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| *ពន្ធពន្យារជាទ្រព្យសកម្ម* | | | | |
| សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន | 27,944 | 113,872 | 22,000 | 88,396 |
| កម្រៃដំណើរការឥណទានពុំទាន់សំរេចបាន | 44,179 | 180,030 | 35,678 | 143,354 |
| សំវិធានធនលើសោធននិវត្តន៍ | 2,949 | 12,017 | 8,990 | 36,122 |
| *ពន្ធពន្យារជាទ្រព្យអកម្ម* | | | | |
| អចលនទ្រព្យ និងបរិក្ខាបរិក្ខារ | (3,448) | (14,051) | (3,565) | (14,324) |
| **ពន្ធពន្យារជាទ្រព្យសកម្ម សុទ្ធ** | **71,624** | **291,868** | **63,103** | **253,548** |

## 13. ប្រាក់កម្ចី

កម្ចីត្រូវបានវិភាគដូចខាងក្រោម៖

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| បុគ្គល | 8,317,500 | 33,893,813 | 7,085,200 | 28,468,334 |
| ស្ថាប័នហិរញ្ញវត្ថុ | 513,983 | 2,094,480 | 1,004,194 | 4,034,851 |
| | **8,831,483** | **35,988,293** | **8,089,394** | **32,503,185** |
| បង្គរការប្រាក់ដែលត្រូវសង | 123,846 | 504,673 | 101,304 | 407,040 |
| **សរុបប្រាក់កម្ចី** | **8,955,329** | **36,492,966** | **8,190,698** | **32,910,225** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

## 13. ប្រាក់កម្ចី (តពីទំព័រមុន)

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| រយៈពេលខ្លី | 6,379,827 | 25,997,796 | 4,636,925 | 18,631,165 |
| រយៈពេលវែង | 2,575,502 | 10,495,170 | 3,553,773 | 14,279,060 |
| | **8,955,329** | **36,492,966** | **8,190,698** | **32,910,225** |

## 14. បំណុលផ្សេងៗ

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| វិសំធានធនលើការកំណត់ពន្ធឡើងវិញ (*) | 88,149 | 359,207 | - | - |
| ថ្លៃវិជ្ជាជីវៈដែលត្រូវសង | 16,005 | 65,220 | 9,600 | 38,573 |
| បុព្វលើអតីតភាពការងារដែលត្រូវសង | 14,743 | 60,078 | 44,948 | 180,601 |
| បង្គរប្រាក់រង្វាន់ដែលត្រូវសង | 10,322 | 42,062 | 16,610 | 66,739 |
| ពន្ធកាត់ទុកដែលត្រូវសង | 10,128 | 41,272 | 8,140 | 32,707 |
| ចំណូលមិនទាន់ទទួលស្គាល់ | 2,350 | 9,576 | 2,350 | 9,442 |
| ផ្សេងៗ | 22,921 | 93,403 | 12,707 | 51,057 |
| | **164,618** | **670,818** | **94,355** | **379,119** |

(*) ទឹកប្រាក់នេះជាកាតព្វកិច្ចពន្ធ ដែលរាប់បញ្ចូលនូវការប្រាក់ និងពិន័យ ចំនួន 96,421 ពាន់រៀល ឬ 23,796 ដុល្លារអាមេរិក និង 260,756 ពាន់រៀល ឬ 64,353 ដុល្លារអាមេរិក ដែលកើតឡើងពីការកំណត់ពន្ធមានកំរិតឡើងវិញ សម្រាប់ការិយបរិច្ឆេទឆ្នាំ2017 និងការកំណត់ពន្ធពេញលេញឡើងវិញគិតពីឆ្នាំ 2010ដល់ឆ្នាំ 2016 រៀងគ្នា។

## 15. មូលនិធិម្ចាស់ភាគហ៊ុន

(i) ចំនួនភាគហ៊ុនត្រូវបានបង្ហាញដូចខាងក្រោម៖

| | *2019* | *2018* |
|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| នាថ្ងៃទី1 ខែមករា | 2,103,000 | 2,103,000 |
| ការបន្ថែមភាគហ៊ុន | 1,490,000 | - |
| **នាថ្ងៃទី31ខែ ធ្នូ** | **3,593,000** | **2,103,000** |

(ii) រាល់ភាគហ៊ុនទាំងអស់ដែលបានចុះបញ្ជី បោះផ្សាយ និងទទួលបាន និងត្រូវបង់ក្នុងតម្លៃចារឹក 1 ដុល្លារអាមេរិក

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល* | *ដុល្លារអាមេរិក* | *ពាន់រៀល* |
| លោកស្រី អ៊ូ សាន | 65.09% | 2,338,554 | 90.19% | 1,896,623 |
| លោកស្រី ឌិត នីតា | 34.91% | 1,254,446 | 9.81% | 206,377 |
| | **100.00%** | **3,593,000** | **100.00%** | **2,103,000** |

នៅថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ2019 ក្រុមប្រឹក្សាភិបាលបានអនុម័តបោះផ្សាយភាគហ៊ុនបន្ថែមចំនួន 1,490,000 ដុល្លារអាមេរិក ដែលការបង្កើនចំនួន1,000,000 ដុល្លារអាមេរិក ធ្វើឡើងតាមរយៈសាច់ប្រាក់ និងចំនួន490,000 ដុល្លារអាមេរិក ធ្វើឡើងតាមរយៈការផ្ទេរពីប្រាក់ចំណេញរក្សាទុក។ ធនាគារជាតិនិងក្រសួង ពាណិជ្ជកម្មបានអនុម័តអោយក្រុមហ៊ុន ធ្វើការកែប្រែលក្ខន្តិកៈក្រុមហ៊ុន លើការបន្ថែមដើមទុន នាថ្ងៃទី30 ខែ កក្កដា ឆ្នាំ2019 និង នាថ្ងៃទី22 ខែតុលា ឆ្នាំ 2019 រៀងគ្នា។

## 16. ទុនបម្រុងបទប្បញ្ញត្តិ

ការប្រៀបធៀបរវាងសំវិធានធនតាមបទប្បញ្ញត្តិ និងសំវិធានធនតាម CIFRS for SMEs មានដូចតទៅ៖

| | *2019* | *2018* |
|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| សំវិធានធនតាមបទប្បញ្ញត្តិ | 324,397 | 279,544 |
| ដកៈសំវិធានធនតាម CIFRS for SMEs | (254,757) | (188,557) |
| **ទុនបម្រុងតាមបទប្បញ្ញត្តិ** | **69,640** | **90,987** |

## 17. ចំណូលការប្រាក់

ចំណូលការប្រាក់ទទួលបានពី៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| ឥណទាន និងបុរេប្រទាន | 2,032,650 | 8,236,298 | 1,636,327 | 6,618,944 |
| សមតុល្យនៅធនាគារជាតិ | 816 | 3,306 | 568 | 2,298 |
| សមតុល្យនៅធនាគារផ្សេងៗ | 879 | 3,562 | 7,025 | 28,414 |
| | **2,034,345** | **8,243,166** | **1,643,920** | **6,649,656** |

## 18. ចំណាយការប្រាក់

ចំណាយការប្រាក់កើតឡើងពី ប្រាក់កម្ចីមានមានកាលកំណត់មានដូចខាងក្រោម៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| រយៈពេលខ្លី | 388,831 | 1,575,542 | 278,052 | 1,124,718 |
| រយៈពេល | 184,570 | 747,879 | 204,913 | 828,875 |
| | **573,401** | **2,323,421** | **482,965** | **1,953,593** |

## 19. ចំណូលប្រតិបត្តិការផ្សេងៗ

| | 2019 | | 2018 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| | | | *(ការរាយការណ៍ឡើងវិញ - កំណត់សម្គាល់លេខ 3)* | |
| ចំណូលពីប្រាក់ពិន័យ | 99,448 | 402,963 | 56,842 | 229,926 |
| ចំណូលទទួលពីជួល | 7,118 | 28,842 | 10,472 | 42,359 |
| (ខាត)ចំណេញពុំទាន់សំរេចបានពីការប្តូររូបិយប័ណ្ណ | (10,638) | (43,105) | 6,601 | 26,701 |
| | **95,928** | **388,700** | **73,915** | **298,986** |

## 20. ចំណាយបុគ្គលិក

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ប្រាក់បៀវត្សរ៍ | 557,557 | 2,259,221 | 472,281 | 1,910,377 |
| ប្រាក់រង្វាន់ | 59,961 | 242,962 | 55,996 | 226,504 |
| ហ្វឹកហាត់បំពេញបន្ថែម | 10,266 | 41,598 | 6,687 | 27,049 |
| បេឡាជាតិរបបសន្តិសុខសង្គម | 13,351 | 54,098 | 11,371 | 45,996 |
| | - | - | 44,948 | 181,815 |
| ចំណាយផ្សេងៗ | 11,252 | 45,593 | 9,799 | 39,636 |
| | **652,387** | **2,643,472** | **601,082** | **2,431,377** |

## 21 ចំណាយរដ្ឋបាលផ្សេងៗ

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ចំណាយការជួល | 104,174 | 422,113 | 99,090 | 400,819 |
| វិសំធានធនសម្រាប់ការកំណត់ពន្ធឡើងវិញ | 88,149 | 357,178 | - | - |
| ចំណាយផ្លូវច្បាប់ និងអ្នកជំនាញ | 41,964 | 170,038 | 14,655 | 59,279 |
| ការដឹកជញ្ជូន និងធ្វើដំណើរ | 31,042 | 125,782 | 33,691 | 136,280 |
| ចំណាយការបង់ពន្ធ | 25,239 | 102,270 | 20,916 | 84,605 |
| ចំណាយសន្តិសុខ | 24,106 | 97,678 | 19,571 | 79,165 |
| ចំណាយទឹក និងអគ្គីសនី | 22,880 | 92,710 | 21,022 | 85,034 |
| ចំណាយសំភារៈការិយាល័យ | 18,031 | 73,062 | 14,660 | 59,300 |
| ចំណាយលើការជួសជុលនិងថែទាំ | 15,316 | 62,060 | 11,325 | 45,810 |
| ចំណាយទូរគមនាគមន៍ | 11,965 | 48,482 | 11,926 | 48,241 |
| ចំណាយទីផ្សារនិងផ្សាយពាណិជ្ជកម្ម | 8,011 | 32,461 | 4,565 | 18,465 |
| ចំណាយលើការថតចម្លងឯកសារ | 1,892 | 7,666 | 1,991 | 8,054 |
| ចំណាយផ្សេងៗ | 15,343 | 62,170 | 7,256 | 29,350 |
| | **408,112** | **1,653,670** | **260,668** | **1,054,402** |

ចំណាយផ្សេងៗមានរួមបញ្ចូល ចំណាយលើធានារ៉ាប់រង សប្បុរសធម៌ និងការបរិចាគកម្រៃជើងសារ និងចំណាយលើសេវាធនាគារ។

## 22. ភាតព្វកិច្ច និង យថាភាព

### *22.1. កាតព្វកិច្ចលើកតិសន្យា*

ក្រុមហ៊ុនមានកាតព្វកិច្ចនៃភតិសន្យាប្រតិបត្តិការទាក់ទង នឹងការជួលអគារក្រោមការរៀបចំកិច្ចសន្យាជួល ដូចខាងក្រោម៖

| | *2019* | | *2018* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| តិចជាង 1 ឆ្នាំ | 90,380 | 366,234 | 82,110 | 329,918 |
| ចាប់ពី 1 ឆ្នាំដល់ 5 ឆ្នាំ | 154,664 | 626,724 | 136,650 | 549,060 |
| | **245,044** | **992,958** | **218,760** | **878,978** |

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន ដែលបណ្តាលអោយមានសភាពមិនច្បាស់លាស់ ដែលកើតមានឡើងនូវភាពខុសគ្នា ក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធត្រូវបានត្រួតពិនិត្យ និងតាមដានអង្កេតដោយអាជ្ញាធរពន្ធដារជាច្រើនដែលផ្តល់លទ្ធភាពតាមច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងបង់ការប្រាក់។ ពន្ធអាចរងនូវការត្រួតពិនិត្យ និងការស៊ើបអង្កេតឡើងវិញ ដោយអាជ្ញាពន្ធដារផ្សេងៗ ដែលអនុញ្ញាតិដោយច្បាប់ ក្នុងការផាកពិន័យ ដាក់ទោស និងពិន័យជាការប្រាក់។

គណៈគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធន មានលក្ខណៈ គ្រប់គ្រាន់ដោយយោងទៅតាមច្បាប់សារពើពន្ធ។ ម្យ៉ាងវិញទៀត អាជ្ញាធរប្រហែលជាមានការបកស្រាយខុសៗគ្នា និងផលប៉ះពាល់ចាប់តាំងពីពេលក្រុមហ៊ុនបានចុះបញ្ជី អាចមានចំនួនច្រើន ។

## 23. ប្រតិបត្តិការ និងសមតុល្យរបស់ភាគីពាក់ព័ន្ធ

ប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុនជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងការិយបរិច្ឆេទ ដែលត្រូវបានបង្កើត ឡើងនៅល័ក្ខខណ្ឌធម្មតា និងសមតុល្យមិនទាន់សងនៅចុងឆ្នាំ មានដូចខាងក្រោម៖

| *ភាគីពាក់ព័ន្ធ* | *សមតុល្យ ឬប្រតិបត្តិការ* | *2019* | | *2018* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ញាតិសម្ព័ន្ធជិតស្និត | | | | | |
| | កម្ចី | 2,500,000 | 10,187,500 | 900,000 | 3,616,200 |
| | បង្គរការប្រាក់ | 5,677 | 23,133 | 2,416.00 | 9,707 |
| | ចំណាយការប្រាក់ | 91,518 | 370,830 | 62,137 | 251,344 |
| គណៈគ្រប់គ្រងជាន់ខ្ពស់ | | | | | |
| | ឥណទាននិងបុរេប្រទាន | 93,539 | 379,020 | 129,567 | 520,600 |
| | បង្គរការប្រាក់ដែលត្រូវទទួលបាន | 995 | 4,031 | 989 | 3,974 |
| | ចំណូលការប្រាក់ | 5,126 | 20,887 | 6,552 | 26,326 |
| | ប្រាក់ខែ | 227,653 | 922,451 | 223,897 | 899,518 |

## 24. ការរាយការណ៍តួលេខប្រៀបធៀបឡើងវិញ

តួលេខប្រៀបធៀបដូចខាងក្រោម ត្រូវបានរាយការណ៍សារជាថ្មី ដើម្បីកែតម្រូវលើកំហុសឆ្គងសម្រាប់ការិយបរិច្ឆេទមុនដូចតទៅ៖

| | *តាមការរាយការណ៍ពីមុន* | *ការធ្វើនិយ័តកម្មឡើងវិញ* | *តាមការរាយការណ៍ឡើងវិញ* |
|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| *របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ* | | | |
| បំណុលពន្ធប្រាក់ចំណេញ | 88,021 | (32,655) | 55,366 |
| *របាយការណ៍លទ្ធផលពេញលេញ* | | | |
| ចំណាយពន្ធប្រាក់ចំណេញ | 53,703 | (32,655) | 21,048 |

## 25. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទតារាងតុល្យការ

ជាមួយនឹងការវិវឌ្ឍន៍យ៉ាងឆាប់រហ័សនិង ការផ្ទុះឡើងនៃវីរុស coronavirus នេះមានប្រទេសជាច្រើនបានតម្រូវឱ្យអង្គភាពនានាកំណត់ឬបញ្ឈប់ប្រតិបត្តិការអាជីវកម្ម និងអនុវត្តការរឹតបន្តឹងការធ្វើដំណើរនិងវិធានការដាក់អោយនៅដាច់ដោយឡែក។ វិធានការណ៍និងគោលនយោបាយទាំងនេះបានប៉ះពាល់យ៉ាងខ្លាំង (ឬរំពឹងថានឹងប៉ះពាល់) សកម្មភាពរបស់អង្គភាពជាច្រើន។ ការផ្ទុះឡើងនៃវីរុសឆ្លង នេះបានកើតឡើងក្នុងពេលវេលាជិតដល់កាលបរិច្ឆេទ នៃការរាយការណ៍ហើយស្ថានភាពបានបន្តវិវឌ្ឍន៍ ឆ្លងកាត់ពេលវេលានាថ្ងៃទី 31 ខែធ្នូឆ្នាំ 2019 ។ នៅពេលកំពុងផ្ទុះឡើងនេះ ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសជាច្រើន ដែលបានរងផលប៉ះពាល់ និងបង្ករអោយមានភាពយឺតយ៉ាវផ្នែកសេដ្ឋកិច្ច ដោយសារការធ្លាក់ចុះទូទាំងពិភពលោក ។ ធនាគារជាតិ នៃកម្ពុជា បានធ្វើការណែនាំធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ធ្វើការយកចិត្តទុកដាក់លើអតិថិជនរបស់ខ្លួនដែលប្រឈមនិងផលប៉ះពាល់ជាក់ស្តែង និងអនុញ្ញាតិធ្វើការកែទម្រង់ឥណទាន លើវិស័យអតិភាពមួយចំនួនដែលបានកំណត់ក្នុងសារាចរណែនាំ។

ក្រុមហ៊ុន គិតថាព្រឹត្តិការណ៍ជុំវិញការផ្ទុះឡើងនៃវីរុស COVID-19 គឺជាព្រឹត្តការណ៍ដែលមិនតម្រូវអោយធ្វើនិយ័តកម្ម ដែលធ្វើអោយប៉ះពាល់លើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុនាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ។ ប៉ុន្តែ ការផ្ទុះឡើងនេះ អាចប៉ះពាល់ជាសារវន្តលើលទ្ធផលហិរញ្ញវត្ថុឆ្នាំ2020 និងការិយបរិច្ឆេទបន្តបន្ទាប់។ ដោយគិតពីការវិវត្តន៍នៃការផ្ទុះឡើងនេះ ក្រុមហ៊ុនមិនទាន់អាចកំណត់បានពីផលប៉ះពាល់លើស្ថានភាព លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ នៅឡើយទេ។ ក្រុមហ៊ុន និងបន្តរពិនិត្យមើលអំពីស្ថានការណ៍ទៅមុខ។

ក្រៅពីការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ពុំមានព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ដែលមានឥទ្ធិពលខ្លាំង លើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ឡើយ។